## មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

## វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា


Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)


# កំណត់ហេតុកិច្ចប្រជុំ ខប់សែលប្រជុំស្ទួល លើកទី ៣

# យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

ថ្ងៃព្រហស្បតិ៍ ទី២៧ ខែតុលា ឆ្នាំ២០០៥

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**ខប់សែល ដំណាក់កាលទី ២**

**COPCEL Phase II**


*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

១. ការពិនិត្យឡើងវិញនូវកំណត់ហេតុកិច្ចប្រជុំខប់សែលខមលើកទី២ (២២ កញ្ញា ២០០៥)

២. សភាពការណ៍ទូទៅជុំវិញការបោះឆ្នោត

៣. ការរៀបចំបោះឆ្នោតព្រឹទ្ធសភា

៤. ការពិភាក្សាជុំវិញលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតជំហានដំបូង

៥. បញ្ហាអត្តសញ្ញាណប័ណ្ណ (ការពិភាក្សាបន្តពីខប់សែលលើកមុន)

៦. សេចក្ដីផ្សេងៗ

ក្នុងនាមជាទីប្រឹក្សានៃវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) និងជាអ្នកសំរបសំរួលកិច្ចប្រជុំខប់សែល លោក **ឱក សេរី សោភក្ដិ៍** បានស្វាគមន៍ដល់សមាជិកអង្គប្រជុំដែលបានចំណាយពេលដ៏មានតម្លៃយាង និងអញ្ជើញចូលរួមក្នុងកិច្ចប្រជុំខប់សែលខម-COPCELCOM លើកទី៣នៃយន្ដការខប់សែលដំណាក់កាលទី២នេះ ។ លោកបានសុំអធ្យាស្រ័យចំពោះសមាជិកអង្គប្រជុំអំពីការយឺតយ៉ាវក្នុងការបញ្ជូនសេចក្ដីព្រាងកំណត់ហេតុខប់សែលខមលើកទី២ជូនសមាជិកអង្គប្រជុំដើម្បីកែសម្រួលមុននឹងពិភាក្សាអនុម័ត ។ លោកបានបញ្ជាក់ថា នេះដោយសារក្រុមលេខាធិការខប់សែលរបស់យើងជាប់បំពេញបេសកកម្មវាយតម្លៃដើម្បីរៀបចំកិច្ចប្រជុំខប់សែលថ្នាក់ខេត្ត-ក្រុងដែលគ្រោងធ្វើនៅ៤ខេត្ត-ក្រុង (តាកែវ កំពត ក្រុងព្រះសីហនុ និងកំពង់ស្ពឺ) នាខែវិច្ឆិកា ឆ្នាំ២០០៥ ខាងមុខនេះ ។ ជាបន្ត លោកបានប្រកាសរបៀបវារៈនៃកិច្ចប្រជុំនេះ ។

មុននឹងចាប់ផ្ដើមពិភាក្សាលើរបៀបវារៈទី១ លោក **អ៊ក គឹមហាន** តំណាងគណបក្សប្រជាជនកម្ពុជាបានមានមតិថា លោកឯកភាពទាំងស្រុងលើរបៀបវារៈប្រជុំនេះ ។ ដោយឡែក លោកបានធ្វើការចាប់អារម្មណ៍បន្តិចលើចំណុចទី២ នៃរបៀបវារៈស្ដីអំពីសភាពការណ៍ទូទៅជុំវិញការបោះឆ្នោត ដោយបញ្ជាក់ថាពីឆ្នាំ២០០៦ រហូតទៅដល់ឆ្នាំ២០០៨ យើងនឹងមានការបោះឆ្នោត៣លើក ក្នុងនោះឆ្នាំ២០០៦ យើងនឹងរៀបចំការបោះឆ្នោតអសកលដើម្បីជ្រើសតាំងសមាជិកព្រឹទ្ធសភាដែលខាង គជប លោកបានកំណត់អំពីកម្មវិធី ឬប្រតិទិនការងារ និងកាលបរិច្ឆេទនៃការបោះឆ្នោតព្រឹទ្ធសភានេះរួចអស់ហើយដែរ ។ ដូច្នេះការបោះឆ្នោតនៅប្រហែលជា៣ខែទៀតទេនឹងមកដល់ហើយ ហើយការរៀបចំស្រង់បញ្ជីឈ្មោះសំរាប់បោះឆ្នោតនេះក៏ឈានចូលមកដល់ដែរ ។ ដូច្នេះហើយនៅក្នុងចំណុចនេះ យើងគួរធ្វើការពិចារណាដោយដាក់បន្ថែមរបៀបវារៈស្ដីពីការបោះឆ្នោតព្រឹទ្ធសភានេះមកធ្វើការពិភាក្សា ឬយ៉ាងណា ព្រោះថារយៈពេលនៅខ្លីណាស់ ។

លោក **ឱក សេរី សោភក្ដិ៍** បានស្វាគមន៍ចំពោះសំណើសុំបន្ថែមរបៀបវារៈស្ដីពីការបោះឆ្នោតព្រឹទ្ធសភាមកធ្វើការពិភាក្សារបស់អ្នកតំណាងគណបក្សប្រជាជនកម្ពុជា ។ ដូច្នេះយើងនឹងបន្ថែមរបៀបវារៈនេះក្នុងកិច្ចពិភាក្សារបស់យើងក្នុងថ្ងៃនេះ ហើយសង្ឃឹមថាឯកឧត្ដមអគ្គលេខាធិការ គជប នឹងធ្វើសេចក្ដីរាយការណ៍អំពីបញ្ហានេះ។ លោកបានជំរាបអង្គប្រជុំថា លោកមានសេចក្ដីរីករាយណាស់ដែលបានទទួលដំណឹងថា គណបក្ស សម រង្ស៊ី បានសំរេចជាផ្លូវការថានឹងចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតព្រឹទ្ធសភាខាងមុខនេះ ។

## ១. ការពិនិត្យឡើងវិញនូវកំណត់ហេតុកិច្ចប្រជុំខប់សែលខមលើកទី២ (២២ កញ្ញា ២០០៥)

ក្នុងរបៀបវារៈទី១នេះ ឯកឧត្តម អ៊ុក ភូរិ ប្រធានគណបក្ស ប្រជាធិបតេយ្យខ្មែរ បានកត់សំគាល់ថា ខ្លឹមសារនៃសេចក្តីព្រាងកំណត់ហេតុធ្វើបានល្អហើយ ប៉ុន្តែនៅមានបញ្ហាខ្លះៗផ្នែកអក្ខរាវិរុទ្ធ ឃ្លាឃ្លោង និងការដកឃ្លាជាដើម។ ដោយសារកំណត់ហេតុកិច្ចប្រជុំនេះត្រូវធ្វើថ្វាយព្រះមហាក្សត្រ និង ស្ថាប័នកំពូលៗរបស់ជាតិ ក៏ដូចជាទៅដល់ថ្នាក់មូលដ្ឋានដែរនោះ ឯកឧត្តមបានសំណូមពរឱ្យខាងលេខាធិការដ្ឋានខប់សែលយកចិត្តទុកដាក់ និងកែលំអឱ្យបានប្រសើរ។

លោក **ឱក សេរី សោភក្តិ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម អ៊ុក ភូរិ ដែលបានមានមតិយ៉ាងល្អលើសេចក្តីព្រាងកំណត់ហេតុនេះ។ លោកទទួលស្គាល់ថា ពិតជាមានបញ្ហាអក្ខរាវិរុទ្ធពិតប្រាកដមែន តែលោកបានបញ្ជាក់ថា មានពាក្យមួយចំនួនក្នុងសម័យឥឡូវគេសរសេរខុសពីសម័យមុន ឬក៏អាចសរសេរបានពីរយ៉ាង ហើយក្រុមលេខាធិការដ្ឋានខប់សែលរបស់យើងគឺជាយុវជនដែលបានរៀនសូត្រនៅក្នុងសម័យឥឡូវ។ ដូច្នេះបញ្ហាអក្ខរាវិរុទ្ធពិតជាកើតមានឡើងមិនខាន តែទោះជាយ៉ាងណាក៏ដោយ លោកបានសំណូមពរឱ្យខាងលេខាធិការដ្ឋានខប់សែលប្រើវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ជាសំអាងដើម្បីជៀសវាងភាពខុសឆ្គង។

## ២. ភាពការណ៍ទូទៅជុំវិញការបោះឆ្នោត

ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គជប បានរាយការណ៍ជូនអង្គប្រជុំពីការងារមួយចំនួនដែល គជប បានធ្វើក្នុងរយៈពេលមួយខែកន្លងមកនេះ ដូចជាការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតព្រឹទ្ធសភា ។ ដោយសារយើងទើបបានបន្ថែមរបៀបវារៈមួយទាក់ទងនឹងការបោះឆ្នោតព្រឹទ្ធសភា ឯកឧត្តមសូមរាយការណ៍នៅក្នុងរប្យបវារៈនេះតែម្តង ។ លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំជាលទ្ធផលបណ្តោះអាសន្ន យើងបានបញ្ចប់ការចុះឈ្មោះជាក់ស្តែងហើយកាលពីថ្ងៃទី ២០ ខែ តុលា ហើយលទ្ធផលដែលយើងទទួលបានពី ១.៤៩០ ឃុំលើ ១.៦២១ ឃុំ យើងចុះឈ្មោះថ្មីបាន ២០៤.០២៨ នាក់ ហើយលុបឈ្មោះបាន ៤៨.៥៨២ នាក់ សរុបទៅអ្នកដែលមានឈ្មោះក្នុងបញ្ជីមានចំនួន ៦.៧០០.៩៣២ នាក់ ហើយបើយើងគិតភាគរយទាំងអស់នៅក្នុងបញ្ជីបោះឆ្នោត និងចំនួនប្រជាពលរដ្ឋដែលយើងប៉ាន់ស្មានអាយុ ១៨ ឆ្នាំឡើងគិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ នេះគឺយើងបាន ៩៣,៩៨ % បើប្រៀបធៀបនឹងឆ្នាំ២០០៤ យើងបានត្រឹមតែចំនួន ៩៣,៦៥ % ប៉ុណ្ណោះ ។ ឯកឧត្តមបានបញ្ជាក់ថា នេះជាតួលេខបណ្តោះអាសន្នទេ ព្រោះយើងនៅសល់ជាង ១០០ ឃុំទៀតដែលពុំទាន់បានទទួលលទ្ធផល ។ សូមជំរាបថា ១០០ ឃុំនោះ មិនមែនបានទទួលលទ្ធផលទាំងអស់ទេ ព្រោះលទ្ធផលចុងក្រោយនៃសប្តាហ៍ចុងក្រោយមិនទាន់បានបញ្ជូនមកដល់ គជប ទេ ហើយការងារជាក់ស្តែងចំពោះមុខ តាមខេត្ត-ក្រុងកំពុងតែត្រួតពិនិត្យលទ្ធផលនៃការចុះឈ្មោះនេះ ហើយបញ្ជូនមក គជប ដើម្បីបញ្ចូលទិន្នន័យ ។ ចំពោះបញ្ជីដំបូងនៅតាមឃុំ-សង្កាត់ភាគច្រើនត្រូវបានបិទផ្សាយកាលពីថ្ងៃទី ២៤ ខែ តុលានេះ។

ដោយឡែក ចំពោះអ្នកសង្កេតការណ៍ពីមុននៅក្នុងតំណាក់កាលចុះឈ្មោះជាក់ស្តែង គឺយើងមានតែ៤អង្គការទេ តែក្រោយមកមានអង្គការមួយទៀតបានមកសុំចុះឈ្មោះ ដូច្នេះមាន៥អង្គការដែលបានមកចុះឈ្មោះសង្កេតការណ៍ពិនិត្យបញ្ជីឈ្មោះបោះឆ្នោតដោយសរុបទៅមានអ្នកសង្កេតការណ៍បោះឆ្នោតចំនួន ៦៥៧ នាក់ មកពី៥អង្គការ ។ ចំពោះតំណាងគណបក្សនយោបាយ ឯកឧត្តមថ្លែងថា មាន៣គណបក្សគឺ គណបក្ស សម រង្ស៊ី គណបក្ស ហ៊្វុនស៊ិនប៉ិច និងគណបក្ស ប្រជាជនកម្ពុជា ដែលមានទាំងតំណាងបំរុង និងតំណាងពេញសិទ្ធិជិត ១.០០០ នាក់ ។

បញ្ហាមួយទៀតទាក់ទងនឹងការបញ្ចូលឈ្មោះក្នុងប្រព័ន្ធកុំព្យូទ័រ គជប បានជ្រើសរើសបុគ្គលិកចំនួន ១០២ នាក់ដើម្បីបំពេញការងារ ភាគច្រើនបំផុតជាការីកុំព្យូទ័រនៅក្នុងមជ្ឈមណ្ឌលកុំព្យូទ័រដើម្បីត្រៀមធ្វើការបញ្ចូលឈ្មោះដែលយើងចុះឈ្មោះថ្មីបាន និងលុបឈ្មោះអ្នកដែលត្រូវលុប ហើយការងារនេះកំពុងតែចាប់ផ្តើម ហើយនៅចុងសប្តាហ៏នេះសំភារៈ និង ឯកសារចុះឈ្មោះមួយចំនួននឹងបញ្ជូនមកដល់មជ្ឈមណ្ឌលកុំព្យូទ័រ ហើយយើងនឹងធ្វើការចុះឈ្មោះនៅដើមខែក្រោយ ។ ការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបានដំណើរការទៅរលូនតាមកម្មវិធីដែលយើងគ្រោងទុក ហើយការងារជាក់ស្តែងនៅមជ្ឈមណ្ឌលកុំព្យូទ័រកំពុងតែបណ្តុះបណ្តាល និងណែនាំការីកុំព្យូទ័រពីរបៀបបញ្ចូលទិន្នន័យ ។ នៅចំណុចនេះ ឯកឧត្តមបានបញ្ជាក់ថា ទិន្នន័យឥឡូវនេះយើងបញ្ចូលតាមហ្វុនអក្សរ Unicode ពីមុនយើងប្រើ ហ្វុន ខែក ហើយដោយយើងដូរប្រព័ន្ធថ្មីផង អញ្ចឹងទេយើងកំពុងសាកល្បងប្រព័ន្ធ និងបណ្តុះបណ្តាលការីកុំព្យូទ័រទាំងអស់ដើម្បីបំពេញការងារឱ្យទាន់ពេលវេលា ព្រោះថាការជួលការីឱ្យមកបំរើការងារបញ្ចូលទិន្នន័យ យើងកំណត់រយៈពេលច្បាស់លាស់ណាស់ ហើយទាមទារឱ្យមានការប៊ិនប្រសប់ដើម្បីបំពេញការងារឱ្យទាន់ពេលវេលា ។

លោក **ឡា ដារ៉ុឌ្ឍ** តំណាងគណបក្ស សម រង្ស៊ី បានសួរឯកឧត្តម ទេព នីថា ថាតើគណបក្សនយោបាយមានសិទ្ធិសុំទិញបញ្ជីឈ្មោះអ្នកបោះឆ្នោតដំបូងបានឬទេ? លោកបានរំលឹកថា កាលពីឆ្នាំ២០០៣ គណបក្ស សម រង្ស៊ី បានសុំទិញបញ្ជីដំបូងរបៀបនេះពី គជប ជាលាយលក្ខណ៏អក្សរ តែឯកឧត្តម អ៊ឹម សួស្តី និង ឯកឧត្តម ទេព នីថា តែងបដិសេធន៍ចំពោះសំណើសុំទិញនោះ។ ដូច្នេះក្នុងកិច្ចប្រជុំនេះ លោកសុំឯកឧត្តម ទេព នីថា មេត្តាបញ្ជាក់ឱ្យបានច្បាស់ ថាតើគណបក្សទិញបានឬមិនបាន បើមិនបានព្រោះហេតុអ្វី ហើយបើទិញបានតើមានតម្លៃប៉ុន្មាន?

ឆ្លើយតបនឹងសំណួររបស់លោក ឡា ដារ៉ុឌ្ឍ ឯកឧត្តម **ទេព នីថា** បានបញ្ជាក់ថា រឿងសុំទិញបញ្ជីដំបូងនេះធ្លាប់បានប្តឹងតវ៉ាដល់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយ គជប មានឯកសារគ្រប់គ្រាន់ ។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ស្អីទៅហៅថាបញ្ជីដំបូង បញ្ជីដំបូងគឺជាបញ្ជីបោះឆ្នោតដែល គជប បានព្រីនចេញពីកុំព្យូទ័រទៅ ដែលជាបញ្ជីចាស់ ឧទាហរណ៏ ឆ្នាំនេះបញ្ជីដំបូងគឺបញ្ជីឈ្មោះឆ្នាំ ២០០៤ យកទៅធ្វើ Update បន្ទាប់មកគេលុបឈ្មោះអ្នកស្លាប់ចេញ ហើយគេធ្វើបញ្ជីថ្មីមួយទៀត ដែលសរសេរដោយដៃចំពោះអ្នកចុះឈ្មោះថ្មី។ គណបក្ស សម រង្ស៊ី បានសុំទិញបញ្ជីសរសេរដោយដៃនេះនៅឆ្នាំបោះឆ្នោត ២០០៣ ។ ត្រង់ចំណុចនេះ ឯកឧត្តមបានបញ្ជាក់ថា បញ្ជីសរសេរដោយដៃមិនមែនជាបញ្ជីដំបូងទេ បញ្ជីដំបូងគឺមានទាំងចាស់មានទាំងថ្មី ហើយឯកឧត្តមធ្លាប់បាននិយាយនៅក្នុងកិច្ចប្រជុំខប់សែលថា ឯកឧត្តមមិនលក់បញ្ជីសរសេរដោយដៃទេ ព្រោះថា ១.៦២១ ឃុំគឺត្រូវយកមក Copy ទាំងអស់ដើម្បីលក់ជូនគាត់ ហើយវាត្រូវបំបែកចេញពីបញ្ជីចាស់ ដូច្នេះ គជប គ្មានមន្ត្រីសំរាប់បំពេញការងារនេះបានទាំងអស់ទេ។ បើសិនជាទិញទាំងដុំយើង Copy ឱ្យទាំងដុំ ហើយយើងអាចយកបញ្ជីដែលមាននៅក្នុងឃុំ បើទិញនៅឃុំគឺក្របខណ្ឌ័តូចៗ យើងងាយស្រួលឱ្យទេ បើទៅទិញ នៅ គជប ទាល់តែ ១.៦២១ ឃុំ ដូច្នេះយើងត្រូវ Copy ឡើងវិញទាំងអស់ តើយើងមានពេលឯណាទៅផ្តល់សេវាកម្មបែបនេះនោះ។ ឯកឧត្តមធ្លាប់បានឆ្លើយតបជាផ្លូវការទៅវិញ ថាបញ្ជីដំបូងមិនមែនមានតែមួយសន្លឹកទេ ហើយការបំបែកដើម្បីលក់ជូនក៏មិនមែនបញ្ជីដំបូងដែរ ព្រោះបានតែបញ្ជីថ្មី ដោយអត់ដឹងថាបញ្ជីចាស់គេលុបប៉ុណ្ណាផង។ តែក្រោយមក ឯកឧត្តមបានសំរេចលក់ជូនទៅតាមពេលវេលាជាក់ស្តែង និងតាមតម្លៃដើមនៃការផលិត តែសូមរង់ចាំពេលបញ្ចូលទៅក្នុងកុំព្យូទ័ររួចសិន ។ គណបក្ស សម រង្ស៊ី បានសុំទិញ CD ព្រោះទិញក្រដាសវាថ្លៃពេក ឯកឧត្តមបានចម្លង CDជូនទៀត ហើយនៅពេលបាន CD គាត់អត់មានកុំព្យូទ័របើកយកបញ្ជីឈ្មោះនោះចេញមកប្រើ ហើយមកសុំឯកឧត្តមឱ្យជួយ ១២ ខេត្តទៀតដើម្បីជួយធ្វើបញ្ជីនេះ ហើយចុងក្រោយគាត់អត់បានមកធ្វើវិញ ។

បញ្ហានេះឯកឧត្តមមានឯកសារគ្រប់គ្រាន់ទាំងអស់ ហើយបញ្ហានេះ ឯកឧត្តមក៏បានឆ្លើយទៅក្រុមប្រឹក្សាធម្មនុញ្ញដែរ ។ ដូច្នេះបញ្ហានេះមិនមែនជាបញ្ហាធំដុំទេ យើងអាចដោះស្រាយបានដោយឈរលើការយោគយល់គ្នា ។ គណបក្ស ហ៊្វុនស៊ិនប៉ិច បានស្នើសុំទិញបញ្ជី ២០០៥ ដូចសមាជិកទាំងអស់បានជ្រាបហើយថា បញ្ជីឈ្មោះអត់ទាន់បញ្ជូនមកដល់ គជប ទេ ហើយឯកឧត្តមបានណែនាំទៅឃុំ-សង្កាត់បើសិនជាគាត់សុំទិញបញ្ជីនោះ សុំពិនិត្យលទ្ធភាពជាក់ស្តែងដើម្បី Copy ជូនគាត់ ហើយបើសិនជាចង់ទិញទាំងមូលនៅ គជប យើងសូមឱ្យគាត់រង់ចាំពេលបញ្ចូលទិន្នន័យក្នុងកុំព្យូទ័ររួចហើយ យើងនឹង Copy ជូន ចង់បានជា CD ឬចង់បានជាក្រដាស បើចង់បានជាក្រដាសយូរណាស់ ព្រោះថាឥឡូវហ្នឹងវាជិត ១៤.០០០ការិយាល័យហើយ ។ ដូច្នេះសមត្ថភាពនៃការផលិតបញ្ជីបោះឆ្នោតដំបូងនេះមានការលំបាក ព្រោះយើងត្រូវការពេលវេលា និងមន្ត្រីទទួលបន្ទុក ហើយបើ CD ក៏អញ្ចឹងដែរ គឺយើងត្រូវបញ្ចូលឈ្មោះនេះឱ្យអស់សិន ។ ឯកឧត្តមជំរាបដែរថា ហេតុអ្វីបានជាបញ្ជីបោះឆ្នោតដំបូងយើងធ្វើការបិទ ទាំងបញ្ជីដោយកុំព្យូទ័រ និងបញ្ជីដោយដៃ ព្រោះដើម្បីចំណេញពេលវេលា ដែលយើងធ្វើការពិនិត្យបញ្ជីឈ្មោះឱ្យឆាប់ចប់ក្នុងរយៈ៣ខែ ប្រសិនបើយើងធ្វើដូចឆ្នាំ ១៩៩៨ បញ្ជីដំបូងគឺយើងមិនមែនធ្វើដូចនេះទេ គឺចុះឈ្មោះនៅឃុំ-សង្កាត់ហើយអស់បញ្ជូនមក គជប ដើម្បីបញ្ចូលទិន្នន័យ ហើយជិតមួយខែបានបញ្ជូនបញ្ជីដំបូងទៅបិទវិញ ។ គជប បានប្តូរនីតិវិធីក្រោយហ្នឹង គឺថាពេលចុះឈ្មោះ យើង Update យើងលុបឈ្មោះក្នុងបញ្ជីហ្នឹងតែម្តង ហើយកាលណាយើងចុះឈ្មោះថ្មី ធ្វើបញ្ជីដោយដៃមួយទៀត ថែមទាំងបិទនៅឃុំ-សង្កាត់តែម្តង ហើយការងារនេះវាចំណេញពេលវេលាទាំងការតាមដាន ទាំងការបញ្ជូនឯកសារមក គជប ដើម្បីបញ្ចូលទិន្នន័យ ហើយនេះជានីតិវិធីដែល គជប បានជ្រើសរើសនៅក្នុងឆ្នាំ ២០០២ ដើម្បីរៀបចំការចុះឈ្មោះបោះឆ្នោតនេះ ។

ឯកឧត្តម **អ៊ុក ភូរិ** បានមានប្រសាសន៍ទាក់ទងនឹងសភាពការណ៍ទូទៅជុំវិញការបោះឆ្នោត ទោះបីជាមានរបៀបវារៈទី៥និយាយអំពីអត្តសញ្ញាណប័ណ្ណក៏ដោយ ។ តាមដែលឯកឧត្តមបានដឹងដើម្បីចុះឈ្មោះបោះឆ្នោត យើងបានពឹងផ្អែកទៅលើអត្តសញ្ញាណ-ប័ណ្ណជាមូលដ្ឋាន ។ ឯកឧត្តមសង្កត់ធ្ងន់ថា នៅប្រទេសគេទូទៅក្នុងពិភពលោកដែលគេចង់ឱ្យការបោះឆ្នោតមានតម្លាភាព និង ចំណេញពេលវេលាទៀតនោះ គេត្រូវមានប័ណ្ណបោះឆ្នោត ហើយប័ណ្ណបោះឆ្នោតនោះ បើយើងចេះធ្វើគឺមានតម្លៃថោកទេ ហើយមានលេខកូដត្រឹមត្រូវ និងមិនចាំបាច់មានរូបថតទៀត ។ ឯកឧត្តមបានសំណូមពរដល់ឯកឧត្តមអគ្គលេខាធិការ គជប មេត្តាប្រាប់ទៅក្រសួងមហាផ្ទៃក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធឱ្យយកចិត្តទុកដាក់លើបញ្ហានេះផង ។ ឯកឧត្តមបានសង្កេតឃើញថា ការធ្វើអត្តសញ្ញាណប័ណ្ណ មានការខុសច្រើនណាស់ដូចជា ខុសឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើតជាដើម ឧទាហរណ៍ជាក់ស្តែង មាននារី ៩ នាក់នៅស្រុកបាធាយ ឈ្មោះ និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ពួកគេគឺខុសទាំងអស់ រវាងឈ្មោះក្នុងសៀវភៅគ្រួសារ និង អត្តសញ្ញាណប័ណ្ណ ហើយនេះមិនអាចយកប្រើការបានទេ។ ឯកឧត្តមមានការបារម្ភមិនដឹងថា ចំនួនអត្តសញ្ញាណប័ណ្ណជាង៦លានសន្លឹកដែលបានចេញនោះអាចខុសពី៤០ទៅ ៥០ភាគរយ ឬ យ៉ាងណាទេ ដោយសារអ្នកដែលទៅសុំធ្វើប័ណ្ណអត់មានឯកសារពាក់ព័ន្ធបង្ហាញសមត្ថកិច្ច ។ ដូច្នេះឯកឧត្តមស្នើធ្វើយ៉ាងណាឱ្យមានភាពស៊ីគ្នារវាងអត្តសញ្ញាណប័ណ្ណ និងសៀវភៅគ្រួសារ និងបញ្ជីជាតិជាដើម ដើម្បីឱ្យមានតម្លាភាពក្នុងការទទួលស្គាល់មនុស្សពិតប្រាកដ ហើយនៅត្រង់ចំណុចនេះ គឺចៀសវាងជាឧទាហរណ៍ប្អូនយកប័ណ្ណបងប្រើ ឬបងយកប័ណ្ណប្អូនប្រើ ។ ម្យ៉ាងទៀត បើយើងធ្វើប័ណ្ណមិនស៊ីគ្នានឹងសៀវភៅគ្រួសារ ឬបញ្ជីជាតិនោះ វាជាចំណុចខ្សោយមួយរបស់អាជ្ញាធរមូលដ្ឋាន ជាពិសេសស្មៀនឃុំ-សង្កាត់ ដែលបានរៀនសូត្រពីក្រសួងមហាផ្ទៃ ហើយបើសិនជាគាត់មិនធ្វើការនេះឱ្យបានហ្មត់ចត់ទេ ប្រជាពលរដ្ឋនឹងជួបបញ្ហាដោយត្រូវធ្វើប័ណ្ណឡើងវិញទាំងអស់ ឬក៏ត្រូវធ្វើសៀវភៅគ្រួសារឡើងវិញដើម្បីឱ្យស៊ីគ្នា។ តែទោះជាយ៉ាងណាក៏ដោយ កន្លងមកប្រជាពលរដ្ឋខ្លះត្រូវបានចំណាយលុយចាប់ពី ២០ ទៅដល់ ១០០ ដុល្លារផងដើម្បីកែតម្រូវ ហើយបើគ្មានប្រាក់មិនអាចធ្វើបានទេ ។

ឯកឧត្តមបានបន្តថា យើងគួរធ្វើអ្វីៗទៀតឱ្យបានដូចសម្តេច **ហ៊ុន សែន** ធ្លាប់បានមានប្រសាសន៍ថា "**ឈ្នះ ឈ្នះ** " គឺឈ្នះទាំងរកការងារធ្វើក៏ឈ្នះ និងសំរាប់ការបោះឆ្នោតក៏ឈ្នះ ។

លោក **ឱក សេរី សោភក្តិ៍** បានសំណូមពរឱ្យសមាជិកទាំងអស់មានមតិទៅតាមរបៀបវារៈប្រជុំ ហើយកុំឱ្យលើកគ្រប់បញ្ហាក្នុងពេលតែមួយ ព្រោះយើងមានរបៀបវារៈច្រើនដែលត្រូវពិភាក្សាគ្នា ហើយបើសិនជាសមាជិកម្នាក់ៗគោរពតាមរបៀបវារៈ យើងមានភាពងាយស្រួលក្នុងការបញ្ចេញមតិ ក៏ដូចជាការឆ្លើយតបទៅនឹងសំណួរផ្សេងៗផងដែរ ជាពិសេសខាងលេខាធិការដ្ឋានក៏មានភាពងាយស្រួលក្នុងការធ្វើសេចក្តីព្រាងកំណត់ហេតុផងដែរ ។ លោកបានបញ្ជាក់ទៀតថា ក្នុងកិច្ចប្រជុំនីមួយៗយើងមានពេលតែ៣ម៉ោងកន្លះទេ បើសិនជាយើងប្រើវាមិនបានល្អ វាប្រាកដជាមិនបានលទ្ធផលគាប់ប្រសើរទេ ។ មុននឹងជូនវេទិកាបន្តទៅសមាជិកអង្គប្រជុំ លោកបានជំរាបថា បើសិនជាសមាជិកណាម្នាក់ចង់ដាក់របៀបវារៈសំរាប់កិច្ចប្រជុំលើកក្រោយ សូមផ្ញើមកលេខាធិការដ្ឋានជាលាយលក្ខណ៏អក្សរ ។

លោក **ឡា ដារុំឌ្ឍ** បានសួរថាបើសិនជាសមាជិកណាម្នាក់ ចង់ស្នើរបៀបវារៈ តើត្រូវធ្វើជាលាយលក្ខណ៏អក្សរមកលេខាធិការដ្ឋានមុនកិច្ចប្រជុំ ឬក៏អាចលើកស្នើក្នុងពេលប្រជុំនេះតែម្តង ? ឆ្លៀតក្នុងឱកាសនេះផងដែរ លោកបានស្នើរបៀបវារៈសំរាប់កិច្ចប្រជុំលើកក្រោយគឺ " អំពីបញ្ជីបោះឆ្នោតដំបូង " ពីព្រោះថាការបកស្រាយរបស់ឯកឧត្តម ទេព នីថា លោកមិនឯកភាពទេ ព្រោះមាត្រា ៦៣ ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោត បានចែងយ៉ាងច្បាស់ណាស់អ្វីទៅហៅថាបញ្ជីបោះឆ្នោតដំបូង ។ ដោយសារកុំឱ្យប្រាសចាកអត្ថន័យ លោកមិននិយាយពីនិយមន័យបញ្ជីបោះឆ្នោតដំបូងទេ នៅក្នុងបទបញ្ជា និង នីតិវិធីរបស់ គជប មានពីរចំណុចទៀតដែលនិយាយច្បាស់ស្អីទៅដែលហៅថាបញ្ជីបោះឆ្នោតដំបូង ហើយ គជប មានភារកិច្ចអ្វីខ្លះជាមួយនឹងគណបក្សនយោបាយ ។ ចំណុចមួយទៀតដែលលោកគិតថាជាការចាំបាច់ដែលត្រូវជជែកគ្នានោះ គឺបទបញ្ជា និង នីតិវិធីមួយចំនួនក្នុងការបោះឆ្នោត ពីព្រោះលោកសង្ឃឹមថាយើងនឹងមិនធ្វើការកែប្រែអ្វីច្រើនទេ តែយើងក៏ត្រូវដឹងពីចំណុចដែលត្រូវកែសំរួលដែរ ។ ចំពោះឯកឧត្តម អ៊ុក ភូរិ បានមានប្រសាសន៍អំពីប័ណ្ណបោះឆ្នោត ចង់ដូរម៉ូដជាថ្មីវាល្អមែនហើយ ប៉ុន្តែបើយើងរវល់តែដូរ ប្រជាពលរដ្ឋតាមមិនទាន់ទេ ។ ទាក់ទងនឹងកំណត់ហេតុនៃការបោះឆ្នោត លោកបានសរសេរជាលាយលក្ខណ៏អក្សរទៅឯកឧត្តម អ៊ឹម សួស្តី ដែរ ថាហេតុអ្វីបានជាកំណត់ហេតុទាំងនោះ ទីបំផុតមានតែភាគីខាង គជប ដែលមានសិទ្ធិរក្សាទុកនូវកំណត់ហេតុច្បាប់ដើមទាំងនោះ ចំណែកខាងគណបក្សនយោបាយទៅជាអត់មានគ្រាន់តែមានច្បាប់ចម្លងដែលគេបានដកស្រង់ចំណុចខ្លះៗឱ្យប៉ុណ្ណោះ គេហៅថា ទំរង់លេខ ១១០៥ ។ លោកបញ្ជាក់ថា យើងធ្វើការជាមួយគ្នា ហើយកំណត់ហេតុយើងចែកឱ្យគ្រប់សមាជិកទាំងអស់ ប៉ុន្តែដល់រឿងបោះឆ្នោតដែលជារឿងមួយសំខាន់បំផុតទៅជារក្សាទុកដោយភាគីម្ខាងទៅវិញ ដូច្នេះសូមឱ្យមានការជជែកគ្នាពីបទបញ្ជា និង នីតិវិធីចំណុចខ្លះឡើងវិញ ។

លោក **ឱក សេរី សោភក្តិ៍** បានសំដែងនូវអំណរគុណចំពោះតំណាងគណបក្ស សម រង្ស៊ី ដែលបានលើកសំណើរបៀបវារៈសំរាប់កិច្ចប្រជុំលើកក្រោយ ហើយសំណើនេះមានសារៈសំខាន់ណាស់ដើម្បីឱ្យសមាជិកម្នាក់ៗត្រៀមឯកសារ និង មតិយោបល់ដើម្បីលើកឡើងក្នុងការពិភាក្សាឱ្យត្រូវចំទិសដៅ ។ ចំពោះការបោះឆ្នោតព្រឹទ្ធសភាឆ្នាំ២០០៦ខាងមុខនេះ លោកយល់ថាដូចជាមិនមានបញ្ហាចោទទេ ព្រោះអ្វីៗ គជប បានរៀបចំក្នុងផែនការការងាររបស់ខ្លួនរួចអស់ហើយ គឺរង់ចាំតែថ្ងៃបោះឆ្នោតមកដល់តែប៉ុណ្ណោះ ។ តែទោះជាយ៉ាងណាក៏ដោយសំរាប់ការបោះឆ្នោតឆ្នាំ ២០០៧ និង ២០០៨ នឹងមានបញ្ហាចំរូងចំរាស់ច្រើនដែលយើងត្រូវជជែកពិភាក្សាគ្នាជាមុនថាតើមានចំណុចត្រង់ណាដែលត្រូវយកមកកែលំអពីពេលឥឡូវនេះទៅ កុំឱ្យដល់ពេលនោះទើបនាំគ្នាប្រញាប់ប្រញាល់ជជែកគ្នានោះ ។ ដូច្នេះ បើសិនជាសមាជិកណាមានសំណើអ្វីសូមដាក់នៅក្នុងផែនការរបស់ខ្លួន ហើយស្នើមកលេខាធិការដ្ឋានខប់សែល ដើម្បីដាក់ក្នុង

របៀបវារៈប្រជុំឱ្យហើយ ។ លោកបញ្ជាក់ថា ការរៀបចំទុកជាមុននេះ អាចជួយ គជប ក្នុងការកែសំរួលបទបញ្ជា និង នីតិវិធីបោះឆ្នោត ព្រមទាំងលិខិតបទដ្ឋានផ្សេងៗផងដែរ ។ ទាក់ទងនឹងក្របខ័ណ្ឌច្បាប់ និងការធ្វើវិសោធនកម្មច្បាប់ លោកបានសង្កត់ធ្ងន់ដែរថា វាត្រូវការពេលវេលាឱ្យយើងយកចិត្តទុកដាក់ពីឥឡូវនេះទៅ ហើយលោកបានសំណូមពរឱ្យខាង CLEC និង CDP ដែលជាអង្គការផ្នែកច្បាប់មេត្តាពិនិត្យមើលថាតើមានមាត្រាណា ជំពូកណានៃច្បាប់បោះឆ្នោត និង បទបញ្ជា និង នីតិវិធីនៃការបោះឆ្នោតដែលគួរកែសំរួលដើម្បីឆ្លើយតបនឹងស្ថានភាពជាក់ស្តែង ហើយលើកជាអនុសាសន៍ជូន គជប និង ស្ថាប័នពាក់ព័ន្ធ ។ ជាបន្ត លោកបានធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃការចុះបំពេញបេសកម្មទៅកាន់៤ខេត្ត-ក្រុង (តាកែវ កំពត ក្រុងព្រះសីហនុ និង កំពង់ស្ពឺ) ដើម្បីវាយតម្លៃមុននឹងរៀបចំកិច្ចប្រជុំខប់សែលថ្នាក់ខេត្ត-ក្រុងនាខែវិច្ឆិកាខាងមុខនេះ ។

ក្រុមបេសកកម្ម ដែលដឹកនាំដោយលោកផ្ទាល់បានជួបសំណេះសំណាលជាមួយឯកឧត្តមអភិបាល-អភិបាលរងខេត្ត-ក្រុង ប្រធានសាខាគណបក្សនយោបាយធំៗទាំងបី ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ប្រធាន-អនុប្រធានអង្គភាពរដ្ឋបាលមូលដ្ឋាន តំណាងកម្មវិធីសីលា ព្រមទាំងអ្នកសំរបសំរួលថ្នាក់ខេត្ត-ក្រុងនៃអង្គការដែលធ្វើសកម្មភាពលើការងារបោះឆ្នោត វិមជ្ឈការ វិសហមជ្ឈការ អភិបាលកិច្ច សិទ្ធិមនុស្ស និងការគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រចាំខេត្ត-ក្រុងទាំង៤ខាងលើនេះ ។ ឆ្លៀតក្នុងឱកាសនោះផងដែរ ក្រុមបេសកកម្មបានជួបពិភាក្សាជាមួយសហការីបណ្តាញ (Focal Persons) នៃខេត្ត-ក្រុងទាំង៤ ស្តីអំពីការងារលំអិតផ្នែករដ្ឋបាលដែលត្រូវជួយក្នុងការរៀបចំកិច្ចប្រជុំខប់សែលនៅថ្នាក់ខេត្ត-ក្រុងនាពេលខាងមុខនេះ។

ក្រុមបេសកកម្មបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅ និងការគាំទ្រយ៉ាងខ្លាំងពីដៃគូពាក់ព័ន្ធខាងលើក្នុងការរៀបចំកិច្ចប្រជុំខប់សែលនៅថ្នាក់ខេត្ត-ក្រុងទាំង៤ របស់វិទ្យាស្ថាន CDRI ដែលគ្រោងធ្វើនៅខែវិច្ឆិកា ឆ្នាំ២០០៥ ខាងមុខនេះ ។ ដៃគូពាក់ព័ន្ធទាំងអស់បានសន្យាថា នឹងអញ្ជើញចូលរួម ព្រមទាំងចាត់តំណាងដើម្បីចូលរួមក្នុងកិច្ចប្រជុំ ខប់សែលថ្នាក់ខេត្ត-ក្រុងនេះ។ ឯកឧត្តមអភិបាល-អភិបាលរងខេត្ត-ក្រុង ប្រធានសាខាគណបក្សនយោបាយធំៗទាំងបី ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ប្រធានអនុប្រធានអង្គភាពរដ្ឋបាលមូលដ្ឋាន និង តំណាងកម្មវិធីសីលា បានឯកភាពគ្នាថានឹងធ្វើយ៉ាងណាឱ្យបញ្ហាធំៗទាំងបីខាងក្រោមមានភាពប្រសើរឡើងជាលំដាប់ក្នុងរយៈពេលបីឆ្នាំខាងមុខ:

១- បញ្ហាអត្តសញ្ញាណប័ណ្ណ : នឹងខំប្រឹងប្រែងធ្វើឱ្យប្រជាពលរដ្ឋដែលដល់អាយុបោះឆ្នោតបានទទួលគ្រប់ៗគ្នា ឯកឧត្តមអភិបាល-អភិបាលរងខេត្ត-ក្រុង បានសន្យាយ៉ាងឧឡារិកថា ចាប់ពីពេលនេះតទៅ នឹងពុំឱ្យមានការយឺតយ៉ាវក្នុងការចុះហត្ថលេខាលើឯកសារទាក់ទងនឹងអត្តសញ្ញាណប័ណ្ណ ។

២- ការងារចុះឈ្មោះអ្នកបោះឆ្នោត : នឹងខំប្រឹងប្រែងធ្វើឱ្យប្រជាពលរដ្ឋដែលដល់អាយុបោះឆ្នោត បានចុះឈ្មោះឱ្យបានជាអតិបរមាក្នុងពេលបីឆ្នាំខាងមុខ ។

៣- បញ្ហាសន្តិសុខ : នឹងខំប្រឹងប្រែងធ្វើឱ្យបរិយាកាសជុំវិញដំណើរការរៀបចំការបោះឆ្នោត ប្រកបដោយសណ្តាប់ធ្នាប់ និងសន្តិសុខ ពុំមានការបំភិតបំភ័យ និងពុំមានការភ័យខ្លាច ។

ក្នុងជំនួបនោះក្រុមបេសកកម្មបានទទួលសំណូមពរ និងអនុសាសន៍ដែលលើកឡើងដោយអង្គការសង្គមស៊ីវិល សំរាប់ការកែលំអ និង ដាក់ក្នុងសំណើរបៀបវារៈនៃកិច្ចប្រជុំខប់សែលនៅថ្នាក់ខេត្ត-ក្រុង ដូចខាងក្រោម:

១. គួរបង្កើនការបណ្តុះបណ្តាលអំពីដំណើរការបោះឆ្នោតដល់ភ្នាក់ងារគណបក្សនយោបាយ ។

២. តួនាទីរបស់ស្មៀនឃុំមិនច្បាស់លាស់ក្នុងកំឡុងពេលការងារចុះឈ្មោះអ្នកបោះឆ្នោត ( ពេលខ្លះកំពុងតែបំពេញការងារចុះឈ្មោះអ្នកបោះឆ្នោត ស្រាប់តែមេឃុំហៅទៅធ្វើការងារផ្សេងទៀតវិញ ) ។

៣. ការជ្រើសរើសមន្ត្រីលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត-ក្រុង មាននិន្នាការនយោបាយលាយឡំ ។

៤. ការជ្រើសរើសមន្ត្រីឃុំ-សង្កាត់រៀបចំការបោះឆ្នោតមិនតម្លាភាព ហើយប្រកាន់បក្សពួក ។

៥. ការចុះឈ្មោះអ្នកបោះឆ្នោតមិនគួរឱ្យស្មៀនឃុំ-សង្កាត់ពាក់ព័ន្ធទេ គឺមន្ត្រីលេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្ត-ក្រុង និងមន្ត្រីឃុំ-សង្កាត់រៀបចំការបោះឆ្នោតគួរជាអ្នកធ្វើដោយផ្ទាល់ ។

៦. គជប មិនគួរប្រើការសម្របសម្រួលពេកទេ ក្នុងការដោះស្រាយបញ្ហាផ្សេងៗក្នុងដំណើរការបោះឆ្នោត គប្បីប្រើនីតិវិធីច្បាប់វិញ ។

៧. ភាពមិនច្បាស់លាស់រវាងការចែកអំណោយនយោបាយនិងអំណោយរបស់កាកបាទក្រហមក្នុងពេលឃោសនាបោះឆ្នោត។

៨. អ្នកមិនទាន់ដល់អាយុ១៨ឆ្នាំ មានសិទ្ធិចុះឈ្មោះបោះឆ្នោត ។

៩. គួរបង្កើនការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងស្មើភាព ។

១០. រយៈពេលនៃការចុះឈ្មោះអ្នកបោះឆ្នោតគួរឱ្យវែងជាងនេះ ។

១១. មានការដូរការិយាល័យបោះឆ្នោត ដោយអ្នកបោះឆ្នោតមិនដឹង ។

១២. សំភារៈសំរាប់ចុះឈ្មោះអ្នកបោះឆ្នោតមិនគ្រប់គ្រាន់ ដែលធ្វើឱ្យដំណើរការចុះឈ្មោះមានការយឺតយ៉ាវ ។

១៣. មានការបកស្រាយខុសៗគ្នារវាងខ្លឹមសារបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ ។

១៤. រយៈពេលប្តឹងតវ៉ាគួរមានរយៈពេលវែងជាងនេះ ។

១៥. គជប ពុំបានប្រើអំណាចឱ្យបានគ្រប់គ្រាន់ដូចដែលច្បាប់បានកំណត់នោះទេ ។

១៦. បញ្ហាមានជនជាតិវៀតណាមចុះឈ្មោះបោះឆ្នោត ។

១៧. មេភូមិ និងមេឃុំ ច្រើនឈរនៅជិតការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ។

១៨. គណបក្សនយោបាយគួរកុំប្រើពាក្យញុះញង់ក្នុងពេលយុទ្ធនាការឃោសនា ។

១៩. បញ្ហាអត្តសញ្ញាណប័ណ្ណទាក់ទងនឹងការចុះឈ្មោះអ្នកបោះឆ្នោត ។

២០. អាជ្ញាធរមូលដ្ឋានត្រូវប្រកាន់ភាពអព្យាក្រឹតក្នុងមុខដំណែង ។

២១. គួរមានការបណ្តុះបណ្តាលអំពីដំណើរការបោះឆ្នោតដល់មេភូមិ ។

លោកបានធ្វើការសន្និដ្ឋានថា បេសកកម្មត្រួតត្រាយផ្លូវខាងលើនេះ ពិតជាមានសារៈប្រយោជន៏ណាស់សំរាប់ការរៀបចំកិច្ចប្រជុំខប់សែលប្រ៉ម-COPCELPROM (ខប់សែលថ្នាក់ខេត្ត-ក្រុង) ជាពិសេសបង្កើនកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធថែមទៀត រវាងវិទ្យាស្ថាន CDRI និងអាជ្ញាធរខេត្ត-ក្រុងគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិល គណបក្សនយោបាយនៅថ្នាក់ខេត្ត-ក្រុង។ បេសកកម្មនេះបានស្វែងយល់នូវចំណុចវិជ្ជមាន និងអវិជ្ជមានក្នុងយន្តការបោះឆ្នោតពីតួអង្គនៅមូលដ្ឋានដោយផ្ទាល់ ហើយបានចូលរួមចំណែកយ៉ាងធំធេងដល់ដំណើរការបោះឆ្នោតនៅកម្ពុជាដើម្បីឱ្យប្រព្រឹត្តទៅមានភាពរលូនស្របតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

## ៣.ការរៀបចំបោះឆ្នោតព្រឹទ្ធសភា

ឯកឧត្តម **ទេព នីថា** បានរាយការណ៍ជូនអង្គប្រជុំអំពីដំណើរការរៀបចំការបោះឆ្នោតព្រឹទ្ធសភាជូនអង្គប្រជុំថា នៅក្នុងខែកន្លងមកនេះ គជប បានបោះពុម្ព និងធ្វើការផ្សព្វផ្សាយពីនីតិវិធីនៃការបោះឆ្នោត ហើយនីតិវិធីនេះ គជប បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ខេត្ត-ក្រុង ។ ឯកឧត្តមបានបញ្ជាក់ថា ដោយសារវាទាក់ទងនឹងបញ្ហាថវិកាមួយចំនួន ការបើកវគ្គបណ្តុះបណ្តាលនេះយើងជ្រើសរើសមន្ត្រីពីខេត្ត-ក្រុងនីមួយៗមកតែ២នាក់ទេ គឺប្រធាន និង អនុប្រធានលេខាធិការដ្ឋានខេត្ត-ក្រុង ហើយបញ្ហានេះវាទាក់ទងនឹងបច្ចេកទេសបន្តិច ព្រោះយើងពុំទាន់បានបង្កើតគណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោតទេ រហូតដល់ថ្ងៃ ០១ ខែ ធ្នូ ទើបបានតែងតាំងគណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត ហើយក្នុងរយៈពេលនៃការចុះឈ្មោះ យើងប្រើប្រាស់លេខាធិការដ្ឋានខេត្ត-ក្រុង ដែលបច្ចុប្បន្នគាត់កំពុងតែធ្វើការចុះឈ្មោះបោះឆ្នោត ។ យើងបានបណ្តុះបណ្តាលមន្ត្រីលេខាធិការដ្ឋានខេត្ត-ក្រុងរៀបចំការបោះឆ្នោតរបស់យើងនៅភ្នំពេញចប់ហើយ ហើយនៅក្នុងនោះក៏មានមន្ត្រីមកពីអគ្គលេខាធិការដ្ឋានរដ្ឋសភាមកចូលរួមដែរ ហើយយើងបានចែកនីតិវិធី និង ធ្វើការផ្សព្វផ្សាយទៅខេត្ត-ក្រុង ហើយខេត្ត-ក្រុងក៏បានធ្វើការផ្សព្វផ្សាយបន្តតាមរយៈអាជ្ញាធរឃុំ-សង្កាត់ ។ ហើយរហូតមកដល់ពេលនេះក្នុងដំណើរការចុះឈ្មោះ និងស្រង់ឈ្មោះក្រុមប្រឹក្សាឃុំ-សង្កាត់មានបញ្ហាមួយចំនួន បញ្ហានៅត្រង់ថានៅឃុំ-សង្កាត់មួយចំនួនមានអ្នកស្លាប់ មានអ្នកត្រូវផ្លាស់ប្តូរ ក៏ប៉ុន្តែពុំទាន់មានឯកសារបញ្ជាក់ពីការផ្លាស់ប្តូរពីក្រសួងមហាផ្ទៃនៅឡើយ ព្រោះថា តាមច្បាប់កាលណាមានស្លាប់ មានការផ្លាស់ប្តូរដែលស្នើមកត្រូវអ្នកលេខរៀងបន្ទាប់ឡើងមកជំនួស ប៉ុន្តែត្រូវមានលិខិតស្នាមត្រឹមត្រូវដើម្បីបញ្ជាក់ ដូចជាសេចក្តីប្រកាសពីក្រសួងមហាផ្ទៃដើម្បីឱ្យអ្នកនោះចូលមកកាន់តំណែងជំនួស។ ឯកឧត្តមបានបញ្ជាក់ថា នៅក្នុងការអនុវត្តន៍ការស្រង់ឈ្មោះនេះ គឺយើងស្រង់ឈ្មោះអ្នកនៅក្នុងតំណែង ដូច្នេះអ្នកដែលស្លាប់ក្តី អ្នកដែលត្រូវផ្លាស់ប្តូរក្តីដោយមិនទាន់មានអ្នកជំនួសថ្មី អ្នកហ្នឹងនៅក្នុងតំណែងដដែល។ អាស្រ័យហេតុនេះ យើងបានណែនាំឱ្យស្រង់ទាំងអស់ ទាំងអ្នកស្លាប់ ទាំងអ្នកដែលត្រូវផ្លាស់ប្តូរ ហើយដែលពុំទាន់មានអ្នកថ្មីជំនួសត្រូវស្រង់ហើយដាក់នៅក្នុងកំណត់ហេតុច្បាស់លាស់ដើម្បីបញ្ជូនមកភ្នំពេញ ។ គជប វាយបញ្ចូលឈ្មោះអ្នកបោះឆ្នោត ហើយឈ្មោះដែលត្រូវបានផ្លាស់ប្តូរ និងអ្នកដែលមិនទាន់មានសេចក្តីប្រកាសយើងស្រង់ឈ្មោះរួចបញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីជំរុញការងារនេះធ្វើការចាត់តាំងឱ្យបានបន្ទាន់ដើម្បីបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ។ បន្ទាប់ពីបានសេចក្តីសំរេច យើងកែនៅភ្នំពេញតែម្តង ទើបបានបញ្ចូលទៅក្នុងបញ្ជីដំបូង ។ ស្តីអំពីការចុះបញ្ជីបេក្ខជន រហូតមកដល់ថ្ងៃនេះយើងបានទទួលការចុះបញ្ជីបេក្ខជនពីគណបក្សប្រជាជនកម្ពុជា ហើយ គណបក្ស ហ្វ៊ុនស៊ិនប៉ិច និង ពីម្សិលម៉្ងៃ គណបក្ស សម រង្ស៊ី ក៏បានទៅសុំទំរង់ដើម្បីចុះបញ្ជីបេក្ខជនគណបក្សនយោបាយដែរ។ សំរាប់ការផ្សព្វផ្សាយនៅក្នុងការបោះឆ្នោតព្រឹទ្ធសភា ឯកឧត្តមថ្លែងថា នៅតំណាក់កាលទី១នេះ ដោយហេតុថាការបោះឆ្នោតព្រឹទ្ធសភាជាការបោះឆ្នោតអសកលលើកដំបូង ហើយខ្លឹមសារនៃការផ្សព្វផ្សាយដំបូងរបស់យើងនេះ គឺគ្រាន់តែជូនព័ត៌មាន ឬក៏ធ្វើការពន្យល់ពីការបោះឆ្នោតព្រឹទ្ធសភាទៅតាមច្បាប់ និង តាមរដ្ឋធម្មនុញ្ញដើម្បីឱ្យប្រជាពលរដ្ឋបានជ្រាបពីតួនាទីរបស់ព្រឹទ្ធសភា និងរបៀបបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភាប៉ុណ្ណោះ ដោយ គជប បានធ្វើ Spots វីដេអូ និង Spots វិទ្យុ ។

បញ្ហាមួយទៀតទាក់ទងនឹង ការឃោសនារបស់គណបក្សនយោបាយ តាមដែលឯកឧត្តមបានដឹង ប្រហែលជាគណបក្សនយោបាយមិនចំណាយថវិកាច្រើនលើសកម្មភាពធំៗនោះទេ ក៏ប៉ុន្តែការរៀបចំរបស់យើងគឺមានលក្ខណៈប្រហែលគ្នានឹងការបោះឆ្នោតតំណាងរាស្ត្រដែរ ហើយនៅចំពោះមុខ យើងនឹងបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពមួយ ដោយអញ្ជើញគណបក្សនយោបាយដែលចុះបញ្ជីបេក្ខជនដើម្បីរៀបចំកម្មវិធីធ្វើការផ្សព្វផ្សាយស្មើភាពតាមវិទ្យុ និង ទូរទស្សន៍ ។

ហើយមានបញ្ហាមួយទៀត គជប នឹងរៀបចំការកំទេចចោលសន្លឹកឆ្នោតដែលយើងប្រើប្រាស់តាំងពីឆ្នាំ ១៩៩៨ នៅក្នុងខែនេះ ឬខែក្រោយ ។ គជប មានគំរោងធ្វើការកំទេចតាំងពីឆ្នាំ ២០០៣មកម្លេះ ប៉ុន្តែដោយសារខ្វះខាតថវិកាទើបយើងមិនអាចធ្វើកើត ហើយឥឡូវនេះដោយសារសន្លឹកឆ្នោតតាំងពី ១៩៩៨ មក វាជិតកន្លះឃ្លាំងទៅហើយ ហើយយើងខ្វះកន្លែងដាក់តវ៉ាន់ ហើយច្បាប់ក៏តម្រូវឱ្យយើងធ្វើតាំងពីឆ្នាំទៅម្លេះ ។ គជប នឹងជូនព័ត៌មានដល់អ្នកសង្កេតការណ៍ ហើយបង្កើតគណៈកម្មការ និង នីតិវិធីដើម្បីធ្វើការដុតបំផ្លាញ ហើយការដុតបំផ្លាញនេះប្រហែលជាយើងនឹងជួលឡគេដើម្បីដុត ហើយយើងមានរៀបចំរបាយការណ៍មួយស្តីពីអ្វីដែលដុត និងអ្វីដែលយើងរក្សាទុក ។

លោក **ឡា ដាវុឌ្ឍ** បានសួរឯកឧត្តម ទេព នីថា ថាតើមានគណបក្សណាក្រៅពីគណបក្សដែលមានកៅអីក្នុងរដ្ឋសភា និងក្រុមប្រឹក្សាឃុំ-សង្កាត់ដាក់ពាក្យចុះឈ្មោះបោះឆ្នោតព្រឹទ្ធសភាដែរឬទេ ? ទាក់ទងនឹងការចុះឈ្មោះក្រុមប្រឹក្សាឃុំ-សង្កាត់ លោកសួរថា តើ គជប គិតយ៉ាងណា ព្រោះមានសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ខ្លះគាត់ចេញពីគណបក្ស ឬ លាឈប់ពីក្រុមប្រឹក្សាឃុំគណបក្សហើយត្រូវបានមេឃុំ-ចៅសង្កាត់គណបក្សផ្សេងការពារឱ្យនៅធ្វើការក្នុងមុខដំណែងដដែល និង ឱ្យចុះឈ្មោះបោះឆ្នោតព្រឹទ្ធសភាទៀត ? លោកបានសួរបន្តថា តើអ្នកចុះឈ្មោះនៅតាមឃុំ-សង្កាត់ទាំងនោះ ខាង គជប អាចឱ្យគណបក្ស សម រង្ស៊ី ដឹងបានទេដើម្បីត្រៀមប្តឹងដោះដូរវិញ ព្រោះរឿងនេះមិនមែនជារឿងអាថ៌កំបាំង ទោះបីពេលខ្លះច្បាប់អត់ចែងច្បាស់ក៏ដោយ ដើម្បីឱ្យរីតតែមានតម្លាភាពគេអាចធ្វើបាន ។

ឯកឧត្តម **ទេព នីថា** បានឆ្លើយតបទៅនឹងសំណួររបស់តំណាងគណបក្ស សម រង្ស៊ី ដូចតទៅ : ១- គណបក្សដែលចង់ដាក់ពាក្យប្រកួតប្រជែងការបោះឆ្នោតព្រឹទ្ធសភាមាន ៤ អាចរួមបញ្ចូលទាំងគណបក្សឯកឧត្តម អ៊ុក ភូរិ ផង តែមកទល់នឹងពេលនេះ គជប បានទទួលពាក្យតែពីគណបក្សប្រជាជនកម្ពុជាតែប៉ុណ្ណោះ ។ ២- បញ្ហាចុះឈ្មោះក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏ដូចជាតំណាងរាស្ត្រ ដូចឯកឧត្តមបានជំរាបអញ្ជើង ការធ្វើនីតិវិធីនេះ គឺគ្រាន់តែធ្វើដើម្បីបំពេញទៅតាមលក្ខខ័ណ្ឌផ្លូវច្បាប់ប៉ុណ្ណោះ ហើយក៏ដូចជាការជូនព័ត៌មានដល់អ្នកត្រូវបោះឆ្នោតដើម្បីដឹងថាគាត់មានសិទ្ធិបោះឆ្នោត ទោះជាគាត់មិនមកចុះឈ្មោះក៏គាត់មានឈ្មោះក្នុងបញ្ជីដែរ តែយើងក៏ត្រូវឱ្យគាត់ដឹងព័ត៌មានពីខ្លួនគាត់ដែលត្រូវបំពេញកាតព្វកិច្ចនេះដែរ ។ ដូច្នេះទោះបីគាត់មិនមកចុះឈ្មោះបោះឆ្នោតក៏ដោយ ក៏ត្រូវស្រង់ឈ្មោះគាត់មកដែរ ។ ចំពោះករណីអ្នកសុំលាឈប់ ហើយគណបក្សរបស់គាត់ឱ្យឈប់ពីតួនាទីក្រុមប្រឹក្សាឃុំហើយនោះ បើពុំទាន់មានការប្រកាសជាផ្លូវការពីក្រសួងមហាផ្ទៃក្នុងការសំរេចថាប្តូរអ្នកហ្នឹងចេញដាក់អ្នកថ្មីជំនួសទេ អ្នកនោះនៅក្នុងមុខតំណែងដដែល ។ បញ្ហានេះឯកឧត្តមថ្លែងថា យើងមានការលំបាកដែរ ឧទាហរណ៍ មានតំណាងរាស្ត្រម្នាក់នោះត្រូវបានគណបក្សរបស់គាត់សុំដូរចេញ ហើយ គជប បានលុបឈ្មោះចេញពីបញ្ជីបេក្ខជនហើយ តែសភាអត់ទាន់អនុម័តតាមបទបញ្ជាផ្ទៃក្នុងរបស់សភាទេ ដូច្នេះអ្នកនោះនៅក្នុងតំណែងដដែល ហើយឯកឧត្តមជឿថាឈ្មោះនោះនៅពេលបោះឆ្នោតព្រឹទ្ធសភា រដ្ឋសភានឹងឱ្យឈ្មោះហ្នឹងមកហើយ ។ តើការដោះស្រាយរបៀបណា រវាងការលុបឈ្មោះចេញពីបញ្ជីបេក្ខជន និង រវាងការមិនទាន់ដកសុពលភាពជាសមាជិករដ្ឋសភា ? ឯកឧត្តមបន្ថែមថា ពាក់ព័ន្ធនឹងផ្លូវច្បាប់មានសមាជិកគណបក្សមួយទៀត ត្រូវបានផាកពិន័យនៅពេលបោះឆ្នោតតំណាងរាស្ត្រចំនួន ៥ លានរៀល ហើយឥឡូវនេះបើសិនគណបក្សដាក់បញ្ជីបេក្ខជននោះមក តើត្រូវដោះស្រាយយ៉ាងម៉េច ? គជប បានដាក់ឯកសារទៅក្រសួងយុត្តិធម៌ ក្រសួងយុត្តិធម៌ប្រាប់ឱ្យដាក់ទៅតុលាការ ឯតុលាការបង្វិលករណីនេះទៅក្រសួងវិញ ។ បើសិនមានករណីនេះទៀត ហើយគណបក្សផ្សេងទៀតប្តឹងមក តើឱ្យ គជប ដោះស្រាយយ៉ាងម៉េច ? ឯកឧត្តមចាប់អារម្មណ៍ថា គជប មិនគួរសំរបសំរួលពេកទេ ហើយលើកក្រោយបើមានបញ្ហានេះប្រហែល គជប ដកសិទ្ធិបោះឆ្នោតគាត់តែម្តង គឺលែងផាកពិន័យហើយ

ព្រោះផាកពិន័យវាអត់មានប្រសិទ្ធិភាព បើដកសិទ្ធិបោះឆ្នោតគឺការសំរេចត្រឹម គជប តែម្តង ។ ការសំរបសំរួលដែល គជប ប្រើកន្លង មកដោយសារ គជប យល់ថា : ទី១ កំរិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ទី២ លទ្ធភាពនៃការផ្តល់ព័តិមានមិនបានដិតដល់ឬក៏ ខ្វះខាត ដោយសារការបោះឆ្នោតមួយទៅការបោះឆ្នោត គជប តែងទទួលការិះគន់ថា ការជូនព័តិមានដល់ប្រជាពលរដ្ឋមិនបានដិត ដល់ ហើយនៅពេលដែលត្រូវពិន័យធ្ងន់ធ្ងរមានលើកសំអាងថាគាត់មិនយល់ ។ ឯកឧត្តមបានទទួលស្គាល់ថា ការសំរបសំរួលមួយចំនួន បានបង្កការលំបាកដល់ គជប វិញ ហើយ គជប កំពុងតែពិនិត្យនីតិវិធីមួយចំនួនដើម្បីជំរុញការដោះស្រាយបញ្ហាឱ្យមានប្រសិទ្ធិភាព ។ ចំពោះការចង់ដឹងបញ្ជីឈ្មោះជាមុននេះ រហូតដល់ពេលនេះ គជប ក៏មិនទាន់ដឹងដែរអំពីសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ណាមួយដែល គណបក្សរបស់គាត់ដកពីតំណែង ព្រោះអត់មានតាម គជប ទេ ។ ដូច្នេះ ឯកឧត្តមមិនអាចជូនព័តិមានបានទេ ហើយរហូតដល់ថ្ងៃនេះ គជប អត់ទាន់បានទទួលបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលគេបញ្ជូនពីឃុំ-សង្កាត់នៅឡើយទេ ។ ហើយការងារនេះ អត់មានលាក់បាំងទេ គឺថាយើងទទួលបញ្ជីមក គឺយើងវាយឯកសារឈ្មោះ បន្ទាប់មកអ្នកណាដែលមិនទាន់គ្រប់លក្ខណៈ យើងសុំទៅក្រសួងមហាផ្ទៃ ហើយ បន្ទាប់មកទៀត យើងនឹងបិទបញ្ជីដំបូង ។ គណបក្សនយោបាយអាចពិនិត្យមើលបញ្ជីដំបូងនៃអ្នកបោះឆ្នោត ហើយធ្វើការប្តឹងតវ៉ាក្នុង ករណីណាដែលសមាជិកនោះត្រូវបានបញ្ឈប់ពីគណបក្សហើយ ឬក៏ពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីជាតំណាងឱ្យសមាជិកក្រុមប្រឹក្សា ឃុំ-សង្កាត់ ឬក៏ជាតំណាងរាស្ត្រ ។

លោក **អ៊ក គីមហាន** បានលើកឡើងនូវចំណាប់អារម្មណ៍ ៥ ចំណុច : ១- លោកមានការភ្ញាក់ផ្អើល និងរំភើបដែលបានអាន កាសែតនិយាយអំពីការចូលរួមក្នុងការបោះឆ្នោតព្រឹទ្ធសភា ព្រមទាំងប្រាប់អំពីការចំណាយក្នុងការបោះឆ្នោតរបស់គណបក្សប្រជាធិប-តេយ្យខ្មែររបស់ឯកឧត្តម អ៊ុក ភូរិ ។ ២- ជាការពិតណាស់ ដូចឯកឧត្តម ទេព នីថា បានលើកឡើងអញ្ចឹងគឺគណបក្សប្រជាជន កម្ពុជាបានដាក់ពាក្យទៅ គជប រួចហើយអំពីការចូលរួមក្នុងការបោះឆ្នោតព្រឹទ្ធសភា។ ក៏ប៉ុន្តែក្នុងការដាក់ពាក្យនេះ គណបក្សប្រជាជន កម្ពុជាបានជួបការលំបាកខ្លះក្នុងការបង់ប្រាក់ចំនួន ១៥លានរៀល ព្រោះពុំបានទទួលសេចក្តីជូនដំណឹងពី គជប ថាតើត្រូវបង់នៅកន្លែង ណា លេខគណនេយ្យប៉ុន្មាន ដែលខុសប្លែកពីឆ្នាំ ២០០៣ ដែល គជប បានជូនដំណឹងដល់គណបក្សនយោបាយ ។ ត្រង់ចំណុចនេះ លោកមិនដឹងថា គជប បានចេញសេចក្តីជូនដំណឹង ឬនៅ ឬមួយចេញហើយតែគណបក្សនយោបាយមិនទាន់បានទទួល ។ លោក បញ្ជាក់ថា សេចក្តីជូនដំណឹងរបស់ គជប មានសារៈសំខាន់ណាស់ ជាពិសេសសំរាប់គណនេយ្យកររបស់គណបក្សដើម្បីបញ្ចេញសាច់ ប្រាក់ ។ ៣- លោកស្នើសុំឱ្យ គជប ចេញជាផ្លូវការនូវទីតាំងការិយាល័យបោះឆ្នោតព្រឹទ្ធសភា ដូចជាមានប៉ុន្មានភូមិភាគ? ក្នុងមួយ ភូមិភាគមានប៉ុន្មានខេត្ត ក្នុងមួយខេត្តមានប៉ុន្មានការិយាល័យ? ប្រសិនជាព័តិមាននេះបានឆាប់កាន់តែប្រសើរ ព្រោះវាមានសារៈ សំខាន់ណាស់សំរាប់គណបក្សនយោបាយ ។ ៤- ការចុះឈ្មោះបោះឆ្នោតព្រឹទ្ធសភាគឺមានសារៈសំខាន់ ទោះបីចំនួនអ្នកបោះឆ្នោតមាន តិចក៏ដោយ ព្រោះវាអាចងាយប៉ះពាល់ទៅដល់ចំនួនកៅអីណាស់ មិនដូចជាការបោះឆ្នោតជ្រើសតំណាងរាស្ត្រ និង ក្រុមប្រឹក្សាឃុំ-សង្កាត់ទេ ។ ដូច្នេះលោកសំណូមពរឱ្យ គជប ពិចារណាឱ្យបានហ្មត់ចត់ ព្រោះបើខុសតែ៣-៤សម្លេងចំនួនកៅអីក៏អាចមានការ ប្រែប្រួលដែរ ហើយកិច្ចការនេះបើយើងមើលមួយភ្លែតហាក់ដូចជាគ្មានបញ្ហាធំដុំទេ តែបើមើលឱ្យស៊ីជំរៅទើបដឹងថាបញ្ហានឹងកើតមាន ឡើងនៅពេលប្រកាសលទ្ធផលក្រោយការបោះឆ្នោតជាមិនខាន ។ ចំណុចដែលពាក់ព័ន្ធនឹងរឿងនេះដែរ គឺករណីសមាជិកសភាម្នាក់ ដែលគណបក្សរបស់គាត់លុបឈ្មោះចេញ តើមានសិទ្ធិបោះឆ្នោតដែរឬយ៉ាងណា ? និងករណីអ្នកដែល គជប បានផាកពិន័យ តើគាត់ មានសិទ្ធិបោះឆ្នោតដែរឬទេ ? ដូច្នេះយើងគួរតែពិភាក្សាគ្នាជាមុនកុំឱ្យដល់ពេលបោះឆ្នោត និង ប្រកាសលទ្ធផលមានការចោទប្រកាន់ គ្នាមិនចេះចប់នោះ ។ ៥- ចំពោះការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ លោកបានបញ្ជាក់ថា បើឃុំ-សង្កាត់នៅជិត៧គណបក្ស

ក្រសួងមហាផ្ទៃ និង គជប អាចក្តាប់បានតែបើឃុំនៅឆ្ងាយៗគឺជាការលំបាក ពេលខ្លះឃុំ-សង្កាត់ ស្រុក-ខ័ណ្ឌមិនចាប់អារម្មណ៍ ដូចជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ណាម្នាក់ស្លាប់ ឬ ផ្លាស់ប្តូរទីលំនៅទៅខេត្តឆ្ងាយ ហើយមេឃុំមិនបានរាយការណ៍ និងសុំផ្លាស់ប្តូរ ហើយនៅពេលជិតដល់ថ្ងៃបោះឆ្នោត គាត់ធ្វើសំណើសុំផ្លាស់ប្តូរ តើយើងអាចធ្វើទាន់ដែរឬទេ ? ហើយ គជប មានបានគិតពីបញ្ហានេះទេ ? លោកបានរំលឹកថា ពេលវេលានៅខ្លីណាស់គួរនាំគ្នាពិចារណាពីពេលនេះទៅ ព្រោះលោកមិនចង់ឮការចោទប្រកាន់នៅពេលក្រោយការបោះឆ្នោតទេ ។

លោក **គីវ ហ៊ន** អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃបានបញ្ជាក់នូវចំណាប់អារម្មណ៍២ចំណុចៈ ទី១. តួនាទីរបស់ស្មៀនឃុំ-សង្កាត់ក្នុងការចុះឈ្មោះអ្នកបោះឆ្នោតមានចែងច្បាស់លាស់ណាស់ក្នុងសេចក្តីប្រកាស។ កិច្ចការនេះ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃបានសហការជាមួយ គជប ក្នុងការកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ស្មៀនឃុំ-សង្កាត់។ ទី២ ការផ្លាស់ប្តូរក្រុមប្រឹក្សាឃុំ-សង្កាត់ គឺយើងធ្វើដោយផ្អែកលើក្របខ័ណ្ឌច្បាប់ ហើយមកទល់នឹងពេលនេះក្រសួងបានប្រថាប់ត្រាលើលិខិតផ្លាស់ប្តូរនោះអស់ហើយ ហើយបានបញ្ជូនទៅថ្នាក់មូលដ្ឋានរួចហើយដែរ។ ក្នុងចំណុចនេះ លោកបញ្ជាក់ថា បើសិនការសុំផ្លាស់ប្តូរនោះមានភាពមិនប្រក្រតី ដូចជាគ្មានពាក្យសុំលាលែង និងការស្នើឈ្មោះអ្នកជំនួសមិនតាមលំដាប់លេខរៀងជាដើមនោះ ក្រសួងត្រូវសួរនាំសុំការបំភ្លឺពីគណបក្សដែលស្នើសុំផ្លាស់ប្តូរនោះ។ ហើយមកដល់ពេលនេះ មានគណបក្សខ្លះមិនទាន់បានបញ្ជូនបញ្ជីឈ្មោះបេក្ខជនត្រៀមបំរុងមកក្រសួងមហាផ្ទៃនៅឡើយផង។

ឯកឧត្តម **ទេព នីថា** បានបញ្ជាក់ថា នីតិវិធីនៃការបង់ប្រាក់ដឹកលំសំរាប់ចុះបញ្ជីគណបក្សគឺដូចគ្នានឹងនីតិវិធីលើកមុនដែរ ដូច្នេះហើយបានជា គជប មិនបានជូនដំណឹងទៀត តែទោះជាយ៉ាងនេះក្តីនាយកដ្ឋានដែលទទួលពាក្យនេះបានជំរាបអ្នកដែលយកពាក្យមកដាក់អំពីលេខកុង និងទីកន្លែងដែលត្រូវបង់ប្រាក់ដែរ។ បញ្ហាទីតាំងការិយាល័យបោះឆ្នោត យើងមានបិទផ្សាយជាផ្លូវការហើយ គឺនៅតាមរដ្ឋសភាក៏មាន នៅតាមលេខាធិការដ្ឋានខេត្ត-ក្រុងក៏មាន ហើយយើងគ្មានគោលការណ៍នឹងចែកជូនទេ តែយើងផ្សាយទូលាយតែម្តង ហើយបើសិនជាគណបក្សណាត្រូវការ គជប នឹងអាចផ្តល់ជូនបាន ។

ទាក់ទងទៅនឹងសំណួរចំពោះអ្នកដែលមិនទាន់ត្រូវបានប្រកាសផ្លាស់ប្តូរដោយក្រសួងមហាផ្ទៃ ខាងក្រសួងមហាផ្ទៃគាត់បានមានប្រសាសន៍ហើយ ហើយ គជប សូមជំរាបថាអ្នកដែលគណបក្សបានសំរេចសុំផ្លាស់ប្តូរហើយ ហើយដែលពុំទាន់មានការប្រកាសពីក្រសួងមហាផ្ទៃ សុំជំរុញការងារនេះឱ្យបានលឿនទៅ ព្រោះថាពេលវេលាមានកំណត់ ព្រោះ គជប ត្រូវផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ១៥ ថ្ងៃមុនបោះឆ្នោត។ ឯកឧត្តមបញ្ជាក់ថា បើសិនគណបក្សមានការផ្លាស់ប្តូរអីបន្ទាន់សូមរៀបចំឯកសារឱ្យបានត្រឹមត្រូវ ហើយផ្ញើមកតាមអាជ្ញាធរ ហើយជូនព័ត៌មានមកតាម គជប ដើម្បីឱ្យ គជប ជួយអន្តរាគមន៍ឱ្យបានលឿន។

ចំពោះបញ្ហាអ្នកបោះឆ្នោតដែលថាអាចមានការលំបាកក្នុងករណីមានការផ្លាស់ប្តូរហើយមិនទាន់ច្បាស់លាស់ យើងបានរៀបចំនីតិវិធីមួយ ក៏ដូចជាបំរុងសំរាប់ការបោះឆ្នោតឃុំនៅពេលខាងមុខដែរ ។ យើងនឹងខិតខំធ្វើការអញ្ជើញអ្នកបោះឆ្នោតឱ្យចំឈ្មោះតែម្តង ដោយបញ្ជាក់ការិយាល័យ ទីតាំងការិយាល័យ លេខការិយាល័យ ។ ចំពោះការបោះឆ្នោតព្រឹទ្ធសភានេះ យើងអាចធ្វើ២នីតិវិធី ទី ១. គឺអញ្ជើញចំឈ្មោះ ទី ២. អញ្ជើញជាបញ្ជីតែមួយតែម្តងសំរាប់ឃុំ-សង្កាត់មួយ ព្រោះថាក្រុមប្រឹក្សាឃុំ-សង្កាត់គាត់នៅឃុំ-សង្កាត់តែមួយគាត់នឹងទៅបោះឆ្នោតក្នុងការិយាល័យតែមួយ។ អញ្ចឹងយើងមាននីតិវិធីនេះមួយដើម្បីបញ្ជាក់ឈ្មោះគាត់ថាមានសិទ្ធិបោះឆ្នោត ហើយពីទីតាំងការិយាល័យ ពីលេខកូដការិយាល័យដែលគាត់ត្រូវទៅបោះឆ្នោត ហើយនៅមានបញ្ហាមួយដែរ ដែលក្រសួងមហាផ្ទៃកំពុងតែខិតខំធ្វើ គឺក្រុមប្រឹក្សាឃុំ-សង្កាត់មួយចំនួនពុំមានឯកសារបញ្ជាក់សំគាល់ខ្លួនថាជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ឬក៏ឯកសារ

បញ្ជាក់អត្តសញ្ញាណផ្សេងទៀតដើម្បីទៅបោះឆ្នោតឱ្យបានគ្រប់គ្រាន់ទេ ។ ហើយឥឡូវយើងកំពុងសហការជាមួយក្រសួងមហាផ្ទៃ និងអាជ្ញាធរខេត្តបញ្ជាក់ទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ធ្វើដូចជាលិខិតសំគាល់ខ្លួនមន្ត្រីរាជការអញ្ជើងដើម្បីឱ្យគាត់ប្រើប្រាស់ឯកសារសំរាប់ទៅបោះឆ្នោត។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ ឯកសារបញ្ជាក់អត្តសញ្ញាណបោះឆ្នោតមិនមែនមានតែឯកសារនេះមួយទេ ឯកសារដែលយើងប្រើប្រាស់ក្នុងការបោះឆ្នោតកន្លងមក យើងនៅតែប្រើប្រាស់ដដែលឱ្យតែឈ្មោះនៅក្នុងឯកសារបញ្ជាក់អត្តសញ្ញាណ និងឈ្មោះក្នុងបញ្ជីបោះឆ្នោតបានត្រឹមត្រូវ។

ចំពោះគណបក្សនយោបាយដែលមានសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ សុំឱ្យគាត់ផ្ទៀងផ្ទាត់ឈ្មោះគាត់នៅក្នុងបញ្ជីឈ្មោះឱ្យបានច្បាស់លាស់ ព្រោះថារហូតដល់ថ្ងៃនេះយើងបានទទួលលិខិតសុំកែឈ្មោះ ឱ្យឈ្មោះប្រើនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ និងឈ្មោះគាត់ប្រើរាល់ថ្ងៃឱ្យដូចគ្នា។ ឯកឧត្តមបានសង្កត់ធ្ងន់ថា សុំឱ្យគណបក្សនយោបាយមេត្តាពិនិត្យមើល ហើយបើសិនជាមានខុស សូមធ្វើលិខិតមក គជប ដោយភ្ជាប់ឯកសារសំអាង ដូចជាបញ្ជីជាតិ ។ល។ យើងនឹងកែជូនឱ្យបានទាន់ពេលវេលា ។

ឯកឧត្តម **អ៊ុក ភូរិ** បានថ្លែងថា គណបក្សប្រជាធិបតេយ្យខ្មែរ ដែលជាគណបក្សមានអាយុជាង៦០ឆ្នាំមកហើយ តែងតែមានចេតនាតាំងពីដើមមកក្នុងការចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។ ក៏ប៉ុន្តែគួរឱ្យសោកស្តាយដែលគណបក្សធំៗធ្វើច្បាប់សម្រាប់តែខ្លួនឯងរួចហៅគេឱ្យចូលរួម ហើយនេះមិនខុសពីហៅកុកឱ្យមកផឹកទឹកដោយខ្លួនដាក់ទឹកនៅលើថាស សួរថាតើកុកវាអាចផឹកកើតដែរឬទេ? ឯកឧត្តមបន្តថា នាំគ្នាធ្វើច្បាប់ឱ្យតែសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់ខ្លួនចំនួន ១១.២៦១ នាក់ និងសមាជិកសភាចំនួន ១២៣ នាក់មានសិទ្ធិបោះឆ្នោត ចុះហេតុអ្វីបានជាមិនអនុញ្ញាតឱ្យអង្គវិជ្ជាជីវៈឯករាជ្យផ្សេងៗទៀតចូលរួមបោះឆ្នោតផង ដែលតាមឯកឧត្តមស្មានអាចមានប្រហែល ៨០ម៉ឺននាក់ដែរ ហើយឯកឧត្តមមិនខ្លាចនឹងចំណាយលុយពី១៨ម៉ឺនដុល្លារ ឬលើសនេះទេសំរាប់ការបោះឆ្នោតនេះ ។ គណបក្សឯកឧត្តមចំណាយលុយចំនួនពី១២ ទៅ១៥ ម៉ឺនដុល្លាររៀងរាល់ឆ្នាំសំរាប់ត្រៀមចូលរួមក្នុងការបោះឆ្នោត ទោះបីដឹងថាគណបក្សនៅតូចក៏ដោយ ក៏ត្រូវខំតស៊ូដែរ ព្រោះមិនចង់ឱ្យគណបក្សនេះស្លាប់ក្រោមការដឹកនាំរបស់ឯកឧត្តមដែលធ្វើនយោបាយជាង៣០ឆ្នាំមកហើយ។ ការតស៊ូនេះគឺមិនអត់ប្រយោជន៍ទេ ឧទាហរណ៍ គណបក្សប្រជាជនកម្ពុជាកាលពីឆ្នាំ១៩៥២ លោកបានទទួលសន្លឹកឆ្នោតបានតែចំនួន ០.៣០ ភាគរយ តែលទ្ធផលនៃការតស៊ូមកទល់ថ្ងៃនេះ លោកបានទទួលខ្ពស់លើសគេ។ ឯកឧត្តមបានជំរាបអង្គប្រជុំផងដែរថា ទោះជាគណបក្សរបស់ឯកឧត្តមមានសម្ព័ន្ធភាពជាមួយគណបក្សប្រជាជនកម្ពុជាក៏ដោយ ក៏គណបក្សឯកឧត្តមមានអត្តសញ្ញាណត្រឹមត្រូវ ឯករាជ្យភាព អធិបតេយ្យភាព និងការទទួលខុសត្រូវដោយខ្លួនឯង ហើយវាមិនដូចនឹងការលើកឡើងរបស់លោក ប៉ែន សុវណ្ណ នោះទេ ។

លោក **អ៊ឹម សហវុឌ្ឍី** បានសុំឱ្យឯកឧត្តម ទេព នីថា បកស្រាយអំពីករណីថា បើសិនមានអ្នកបោះឆ្នោតព្រឹទ្ធសភាណាម្នាក់មានគ្រោះថ្នាក់អ្វីមួយដល់ជីវិតក្នុងពេលធ្វើដំណើរទៅបោះឆ្នោត ឬនៅមុនថ្ងៃបោះឆ្នោតមួយថ្ងៃ ឬពីរថ្ងៃ ដល់ពេលនោះតើខាងនីតិវិធី និងគោលការណ៍ច្បាប់ដោះស្រាយយ៉ាងម៉េច ដើម្បីរកអ្នកដែលទៅជំនួសអ្នកដែលមានគ្រោះថ្នាក់ដល់ជីវិតនោះ?

លោក **កាំង សុវណ្ណារេន** មន្ត្រីច្បាប់នៃគណៈកម្មាធិការខុមហ្វ្រែល បានសួរឯកឧត្តមអគ្គលេខាធិការ គជប អំពីការទិញសន្លឹកឆ្នោត។ ដោយសារច្បាប់បោះឆ្នោតព្រឹទ្ធសភា មានមាត្រាចែងអំពីទោសបញ្ញត្តិ ហើយក្នុងនោះមានចែងអំពីការទិញសន្លឹកឆ្នោតដោយសំភារៈ និងដោយលុយកាក់។ ក្នុងដំណើរការបោះឆ្នោតខាងមុខនេះ ឧទាហរណ៍ថាខាងគណបក្សនយោបាយ ឬ បេក្ខជនគាត់ផ្តល់លុយឱ្យទៅក្រុមប្រឹក្សាឃុំ-សង្កាត់ដែលជាអ្នកបោះឆ្នោត ដូចជាសោហ៊ុយធ្វើដំណើរពីឃុំទៅខេត្តដើម្បីទៅបោះឆ្នោត ឬក៏នៅក្នុង

រូបភាពណាក៏ដោយ សួរថាតើការផ្តល់នេះជាការទិញសន្លឹកឆ្នោតដែរឬទេ? តើនៅពេលដែលមានពាក្យបណ្តឹងចោទប្រកាន់ ថានេះជាករណីទិញសន្លឹកឆ្នោត តើខាង គជប មានការបកស្រាយយ៉ាងដូចម្តេច?

លោក **គីម ចន្ទ័សុមិត្រ** សមាជិកគណៈកម្មាធិការនាយក នៃគណបក្ស សម រង្ស៊ី បានសួរឯកឧត្តមតំណាង គជប ថាមានបេក្ខជនតំណាងរាស្ត្រម្នាក់របស់គណបក្សលោកត្រូវបានគណបក្សដកសមាជិកភាពសភាតំណាងរាស្ត្រ ហើយខាង គជប ក៏បានចេញជាសេចក្តីប្រកាសមួយបានទទួលស្គាល់សំណើដកបេក្ខភាពនេះដែរ ប៉ុន្តែនៅខាងសភាវិញនៅតែទទួលស្គាល់បុគ្គលនោះថាជាតំណាងរាស្ត្រដដែល។ ហើយនៅពេលចាប់ផ្តើមចុះឈ្មោះបោះឆ្នោតបុគ្គលនោះនឹងទៅចុះឈ្មោះ តើ គជប ត្រូវសំរេចយ៉ាងណា ឧទាហរណ៍ត្រូវប្រកាន់យកតាមសេចក្តីសំរេចរបស់ខ្លួន ឬត្រូវប្រកាន់យកតាមសេចក្តីសំរេចរបស់រដ្ឋសភា?

ឯកឧត្តម **ទេព នីថា** បានឆ្លើយតបនឹងសំណួររបស់សមាជិកអង្គប្រជុំដូចខាងក្រោមៈ
ឯកឧត្តមបានជំរាបថា ក្រោយពីការផ្តល់សុពលភាពនៃបញ្ជីបោះឆ្នោតហើយ គឺមិនអាចផ្លាស់ប្តូរបានទេ ហើយការផ្តល់សុពលភាពនៃបញ្ជីបោះឆ្នោតនេះ ច្បាប់តម្រូវឱ្យធ្វើ ១៥ ថ្ងៃមុនថ្ងៃបោះឆ្នោត អញ្ចឹងទេការផ្លាស់ប្តូរនេះគឺចាប់ផ្តើមពីពេលបិទបញ្ជីដំបូងគឺ ៤៨ ថ្ងៃមុនបោះឆ្នោត ហើយនៅក្នុងករណីបិទបញ្ជីដំបូងបើសិនជាមានក្រុមប្រឹក្សាឃុំ-សង្កាត់ គាត់ស្លាប់ ហើយគាត់ត្រូវផ្លាស់ប្តូរដោយមូលហេតុហ្នឹង គណបក្សអាចបណ្តឹងតវ៉ា ឬក៏អាចសុំធ្វើការផ្លាស់ប្តូរ ដោយធ្វើឯកសារទៅក្រសួងមហាផ្ទៃឱ្យបាន បន្ទាន់បំផុតតាមរយៈមេឃុំ-ចៅសង្កាត់តាមឋានានុក្រមរបស់គេ ហើយជូនដំណឹងមក គជប ឱ្យបានដឹងថាអ្នកនេះសុំផ្លាស់ប្តូរ ហើយដើម្បីឱ្យ គជប ជួយអន្តរាគមន៍ឱ្យបានទាន់ពេលវេលា។ គជប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតគឺ ១៥ ថ្ងៃមុនថ្ងៃបោះឆ្នោត ហើយរយៈពេលបិទបញ្ជី ដំបូងរហូតទៅមុនការផ្តល់សុពលភាពគឺអាចជូនព័ត៌មាន ឬការប្តឹងសុំផ្លាស់ប្តូរឈ្មោះឱ្យបានត្រឹមត្រូវហើយ ការសុំកែឈ្មោះក្រុមប្រឹក្សាឃុំ-សង្កាត់ ឬសភាដែលសរសេរខុសអក្ខរាវិរុទ្ធមួយចំនួនហ្នឹងត្រូវមានឯកសារមកបញ្ជាក់ច្បាស់ ឧទាហរណ៍ មានបញ្ជីជាតិ និងអត្តសញ្ញាណប័ណ្ណជាតិខ្មែរច្បាស់លាស់ទើបអាចកែទៅបាន ព្រោះថាឈ្មោះនេះយើងស្រង់មកពីឈ្មោះបេក្ខជនដែលគាត់ដាក់ពាក្យសុំបោះឆ្នោត ហើយឈ្មោះទាំងអស់ដែលបានជាប់ជាសមាជិកសភា ជាប់ជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់សុទ្ធតែឈ្មោះដែលប្រជាពលរដ្ឋគាត់បានបោះឆ្នោតឱ្យហើយ។ អញ្ចឹងបើការផ្លាស់ប្តូរណាមួយគ្មានឯកសារច្បាស់លាស់ទេ គឺ គជប មិនអាចប្តូរជូនបានទេ ។

ចំពោះការទិញសន្លឹកឆ្នោត ឯកឧត្តមថ្លែងថា បទបញ្ជា និងនីតិវិធីរបស់ គជប បានចែងហើយ គឺប្រហាក់ប្រហែលគ្នានឹងការបោះឆ្នោតតំណាងរាស្ត្រដែរ ហើយក្នុងកិច្ចប្រជុំពីខែមុនឯកឧត្តមក៏បាននិយាយដែរអំពីនិយមន័យ នៃការទិញសន្លឹកឆ្នោត ហើយយើងមិនអាចឱ្យនិយមន័យលំអិតខ្លាំងពេកទេ។ ព្រោះថាបញ្ហានេះល្អិតពេក ជួនកាលមានល្អិតជាងហ្នឹងទៀតដែលវាមិនអាចបញ្ចូលទៅក្នុងអ្វីមួយបានដើម្បីដោះស្រាយ។ ឯកឧត្តមបានអរគុណចំពោះអង្គការមួយចំនួនដែលបានដកស្រង់និយមន័យនៃការទិញសន្លឹកឆ្នោតពីប្រទេសផ្សេងៗមួយចំនួនប្រគល់មកឱ្យ គជប ។

ទាក់ទងទៅនឹងការផ្តល់សោហ៊ុយ ឬការដឹកជញ្ជូនអ្នកបោះឆ្នោតនេះឯកឧត្តមជឿថាគណបក្សនយោបាយមួយចំនួនដែលមានសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់កំពុងបង្កលក្ខណៈឱ្យសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់ខ្លួនមានលទ្ធភាព មានមធ្យោបាយឡើងមកបោះឆ្នោត ហើយការធ្វើបែបនេះមិនមែនជាការទិញសន្លឹកឆ្នោតទេកុំឱ្យតែធ្វើនៅក្នុងរយៈពេលឃោសនាបោះឆ្នោត។ កន្លងមកយើងបានជជែកគ្នាអញ្ចឹង គឺថាការងារមួយចំនួនមុនពេលឃោសនាបោះឆ្នោតវាជាសកម្មភាពរបស់គណបក្សនយោបាយ តែក្នុងពេលឃោសនាបោះឆ្នោត យើងហាមការចែកអំណោយដូចមានចែងក្នុងនីតិវិធីមុនអញ្ចឹង ។ ហើយកន្លងមកមានបញ្ហារំលោភ យើងក៏បានដោះស្រាយ ដូច្នេះបញ្ហានេះឯកឧត្តមជឿថា នៅក្នុងនីតិវិធី ឬក្រមសីលធម៌នៃគណបក្សនយោបាយ គជប ក៏បន្ធូរបន្ថយច្រើនដែរក្នុង

ការដឹកជញ្ជូនអ្នកបោះឆ្នោតតាំងពីបោះឆ្នោតតំណាងរាស្ត្រមក គឺថាយើងមិនចង្អៀតចង្អល់ពេកទេ ព្រោះថាលទ្ធភាពប្រជាពលរដ្ឋក្នុងការទៅបោះឆ្នោត និងលទ្ធភាពក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការទៅបោះឆ្នោតមានកំរិតហើយមធ្យោបាយធ្វើដំណើរឬក៏ផ្លូវទៅបោះឆ្នោតវាអាចកន្លែងខ្លះ ៥ គីឡូម៉ែត្រពីទីលំនៅរបស់គាត់ តែធ្វើយ៉ាងណាកុំឱ្យរូបភាពហ្នឹងទៅជារូបភាពសមូហភាព ។ កន្លងមកមធ្យោបាយដឹកជញ្ជូនឯកជនធម្មតាយើងអនុគ្រោះ អញ្ចឹងបញ្ហានេះយើងនឹងពិនិត្យ ហើយនៅមុនពេលឃោសនាបោះឆ្នោត យើងនឹងធ្វើការប្រជុំជាមួយគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីជំរាបជូនបញ្ហានេះឱ្យបានយល់ទាំងអស់គ្នាជៀសវាងកើតមានបញ្ហាដែលយើងមិនបានដឹង។

ទាក់ទងនឹងតំណាងរាស្ត្រដែលត្រូវបានលុបចេញពីបញ្ជីបេក្ខជន ឯកឧត្តមបានជំរាបថា គជប លុបដោយឈរលើ ទី១. បានទទួលលិខិតស្នើសុំពីគណបក្សនយោបាយ ហើយការងារនេះឯកឧត្តមបញ្ជាក់ថា គជប លុបឈ្មោះពីបេក្ខជនជាប់ឆ្នោត មិនមែនលុបឈ្មោះតំណាងរាស្ត្រទេ។ ព្រោះថាពេលបោះឆ្នោតជាប់ហើយ គជប គ្រាន់តែធ្វើបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោត អញ្ចឹងបេក្ខជនជាប់ឆ្នោតមិនទាន់ទៅជាតំណាងរាស្ត្រទេ ទាល់តែសភាផ្តល់សុពលភាពតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនទៅជាតំណាងរាស្ត្រ ។ អញ្ចឹងទេរហូតដល់ពេលនេះ គជប បានធ្វើតាមសំណូមពរហើយ ហើយក៏មានសេចក្តីសំរេចបញ្ជូនទៅរដ្ឋសភាហើយ ហើយគណបក្សនយោបាយដែលបានស្នើសុំផ្លាស់ប្តូរសមាជិករបស់ខ្លួនក៏ធ្វើតាមរយៈរដ្ឋសភាមកដែរ។ អញ្ចឹងទេយើងបានធ្វើលិខិតឆ្លើយតបទៅវិញ ដោយជូនសេចក្តីសំរេចទី ១. លុបឈ្មោះបេក្ខជនជាប់ឆ្នោត និងទី ២. ដាក់ឈ្មោះបេក្ខជនបន្ទាប់ជូនទៅហើយ ដូច្នេះបញ្ហានេះកំពុងស្ថិតនៅក្នុងដៃរដ្ឋសភាឯណោះទេ ។

## ៤. ការពិភាក្សាជុំវិញលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតជំហានដំបូង

ឯកឧត្តម **ទេព នីថា** បានជំរាបជូនមួយចំនួនហើយទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។ តួលេខរបស់ក្រសួងមហាផ្ទៃមិនដូចគ្នាជាមួយ គជប ចំពោះអ្នកដល់អាយុ១៨ឆ្នាំឡើងគិតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥។ គជបបានធ្វើការប៉ាន់ស្មានអ្នកដល់អាយុ១៨ឆ្នាំមានចំនួន ១៤០.៤០២ នាក់ ហើយតួលេខខាងក្រសួងមហាផ្ទៃប្រហែលជាលើសតួលេខ គជបជាង២ម៉ឺននាក់។ ឯកឧត្តមបញ្ជាក់ថា តួលេខប៉ាន់ស្មាននេះ គឺយើងបានស្រង់ស្ថិតិដោយលេខាធិការដ្ឋានខេត្ត-ក្រុងសហការជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងស្មៀន ហើយឯកឧត្តមជឿថា តួលេខនេះវាអាចលើសឬអាចខ្វះ។ ដូច្នេះតួលេខនេះមិនមែនជាតួលេខផ្លូវការទេ តែជាតួលេខបង្គោលមួយដើម្បីយើងអនុវត្តន៍ការងារ និងធ្វើផែនការ។ បើយើងគិតតួលេខត្រឹម ១៤ម៉ឺននាក់ហ្នឹងនោះការចុះឈ្មោះឆ្នាំនេះបាន២០ ម៉ឺននាក់ហ្នឹងគឺថាយើងបានចុះឈ្មោះលើសចំនួនដែលយើងប៉ាន់ស្មាន ហើយដូចសមាជិកអង្គប្រជុំបានជ្រាបហើយថា អ្នកដែលត្រូវចុះឈ្មោះបោះឆ្នោតនៅក្នុងឆ្នាំនេះប្រហែលជា ៥៨ ម៉ឺននាក់បើយើងគិតអ្នកដែលសល់តាំងពីណាពីណើរហូតមកព្រោះថាយើងមិនដែលចុះឈ្មោះបាន ១០០ភាគរយទេតាំងពីមុនមក គឺមានសល់មួយឆ្នាំ ២០-៣០ ម៉ឺននាក់រហូត។ ដូច្នេះបើកាលណាយើងប៉ាន់ស្មានថ្មីថែមទៀត វាត្រូវបូកជាមួយលេខចាស់ អញ្ចឹងទេយើងគិតតែអ្នកដែលគ្រប់អាយុតែម្តង យើងចុះឈ្មោះបានច្រើនតែបើគិតលេខចាស់ដែលនៅសល់នេះ គឺយើងចុះបានមិនដល់ ៥០ ភាគរយទេ ។ ក្នុងការចុះឈ្មោះនេះ ស្មៀនឃុំ-សង្កាត់គាត់ខិតខំធ្វើការណាស់ ទោះបីជាគាត់មានភារៈកិច្ចមមាញឹកជាមួយក្រុមប្រឹក្សាក៏ដោយ។ ឯកឧត្តមបានបញ្ជាក់ថា ការចុះឈ្មោះឆ្នាំមុនចំណាយ

ថវិកា អស់ប្រហែល៩២ម៉ឺនដុល្លារ ជាពិសេសចំណាយលើការបណ្តុះបណ្តាលស្មៀនឃុំ-សង្កាត់លើការងារចុះឈ្មោះបោះឆ្នោតចាប់ពីថ្នាក់ គជប រហូតដល់ថ្នាក់ខេត្ត និងថ្នាក់ស្រុកទៀត។ តែទោះជាយ៉ាងណាក៏ដោយ ឯកឧត្តមថ្លែងថា នឹងខិតខំធ្វើយ៉ាងណាឱ្យការចុះឈ្មោះនេះ មានភាពកាន់តែប្រសើរឡើងសំរាប់ការបោះឆ្នោតលើកក្រោយ។

លោក **គឹម ច័ន្ទសុមិត្រ** បានសំណូមពរដល់ គជប មេត្តាបិទបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅតាមការិយាល័យដើម្បីងាយស្រួលឱ្យប្រជាពលរដ្ឋទៅពិនិត្យមើល ហើយបើសិនបិទនៅតាមសាលាឃុំ-សង្កាត់ គឺមានភាពលំបាកដល់ពួកគាត់ ព្រោះរវាងពីឃុំមួយទៅឃុំមួយទៀតមានចម្ងាយឆ្ងាយខ្លះរហូតជាង១០គីឡូម៉ែត្រឯណោះ។ ចំណុចនេះបានធ្វើឱ្យមានបញ្ហានៅពេលបោះឆ្នោត ព្រោះពេលខ្លះឈ្មោះរបស់ពួកគេត្រូវសរសេរខុស ឬពុំមានឈ្មោះតែម្តង ដោយសារមិនបានទៅមើលឈ្មោះជាមុន។

លោក **កុយ ច័ន្ទដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មាន នៃគណៈកម្មាធិការខុមហ្វ្រែលបានបញ្ចេញចំណាប់អារម្មណ៍ថាការចុះឈ្មោះនេះហាក់ដូចជាពុំមានបញ្ហាចោទទេសំរាប់អ្នកដែលមានទីលំនៅជាអចិន្ត្រៃយ៍ ប៉ុន្តែសំរាប់កម្មកររោងចក្រ កម្មករសំណង់ និស្សិត អ្នកធាក់ស៊ីក្លូដែលមកពីបណ្តាខេត្តឆ្ងាយៗមានការលំបាកក្នុងការចុះឈ្មោះបោះឆ្នោត ជាពិសេសកម្មកររោងចក្រ ទោះបីជាក្រសួងសង្គមកិច្ចបានជូនដំណឹងទៅថៅកែរោងចក្រឱ្យអនុញ្ញាតច្បាប់ដល់កម្មករដើម្បីធ្វើដំណើរទៅចុះឈ្មោះក៏ដោយ ក៏សេចក្តីជូនដំណឹងនោះពុំមានប្រសិទ្ធិភាពដែរ។ រីឯអ្នកមានមុខរបរផ្សេងៗទៀតពុំមានពេលវេលាទៅចុះឈ្មោះ ឬមិនចាប់អារម្មណ៍ ដូច្នេះសូមឱ្យ គជប មេត្តាធ្វើយ៉ាងណាដោះស្រាយបញ្ហានេះដើម្បីកុំឱ្យពួកគាត់បាត់សិទ្ធិ។

លោក **កាំង សុវណ្ណារេន** សុំឯកឧត្តមអគ្គលេខាធិការ គជប ឱ្យបកស្រាយអំពីភាពខុសគ្នានៃនីតិវិធីចុះឈ្មោះបោះឆ្នោតឃុំ-សង្កាត់ និងបោះឆ្នោតតំណាងរាស្ត្រ ។ លោកបានលើកឧទាហរណ៍មកបញ្ជាក់ថា អ្នកដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន បើយោងតាមច្បាប់បោះឆ្នោតតំណាងរាស្ត្រ គឺគាត់មិនមានសិទ្ធិចុះឈ្មោះទេ ព្រោះគេចែងថាគាត់ស្ថិតនៅក្នុងស្ថានភាពជាប់ពន្ធនាគារ ប៉ុន្តែបើតាមច្បាប់បោះឆ្នោតឃុំ-សង្កាត់វិញ គាត់នៅមានសិទ្ធិចុះឈ្មោះនៅឡើយ។

លោក **ឡា ដារុំឍ** បានសួរឯកឧត្តមអគ្គលេខាធិការ គជប ថាហេតុអ្វីបានជាចំនួនថ្ងៃចុះឈ្មោះបោះឆ្នោតមានការប្រែប្រួលពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ? ឧទាហរណ៍នីតិវិធី គជប ត្រង់ប្រការ ៧.៣២.២ ចែងថា "ចាប់ពីឆ្នាំ២០០៤ ការចុះឈ្មោះមានរយៈពេល២៨ថ្ងៃ" តែជាក់ស្តែងក្នុងពេលថ្មីៗនេះម្តង២០ ថ្ងៃ ម្តង ១៧ ថ្ងៃទៅវិញ តើនេះឈរលើមូលដ្ឋានអ្វី? លោកបានថ្លែងថាបើសិនសរសេរយ៉ាងណា គជប គួរធ្វើយ៉ាងនោះ។ លោកបានសួរទៀតថា តើមកទល់នឹងពេលនេះ មានប្រជាពលរដ្ឋខ្មែរនៅបរសេទសមកចុះឈ្មោះបោះឆ្នោតដែរឬទេ? បើមានតើចំនួនប៉ុន្មាន? បើយោងលើរដ្ឋធម្មនុញ្ញ ពួកគេមានសិទ្ធិដូចពលរដ្ឋខ្មែរក្នុងស្រុកដែរ។ លោកបានថ្លែងថា ចំនួនអ្នកមកចុះឈ្មោះបោះឆ្នោតមិនសមាមាត្រនឹងចំនួនថវិកាដែល គជប បានចំណាយទាល់សោះ។ ចំណុចចុងក្រោយលោកបានសួរ គជប ថាតើការចុះឈ្មោះអ្នកបោះឆ្នោតនៅប៉ោយប៉ែតនោះយ៉ាងណាហើយ ព្រោះឃុំនោះមានចំនួនមនុស្សច្រើនណាស់។

ឯកឧត្តម **អ៊ុក ភូរិ** បានមានចំណាប់អារម្មណ៍២ចំណុចលើការលើកឡើងរបស់សមាជិកអង្គប្រជុំដូចតទៅៈ ទី១. ការអនុញ្ញាតឱ្យប្រជាពលរដ្ឋខ្មែរនៅបរទេសមានសិទ្ធិបោះឆ្នោតគឺមានសារៈសំខាន់ណាស់ ហើយឯកឧត្តមសូមគាំទ្រនូវគំនិតនេះ ។ តាមដែលឯកឧត្តមគិតត្រួសៗមានប្រជាពលរដ្ឋខ្មែរនៅបរទេសដែលមានសិទ្ធិមិនតិចជាង ៤០ម៉ឺននាក់ទេ ដូច្នេះសិទ្ធិនេះមិនគួរត្រូវបានគេផាត់ចោលនោះទេ។ ទី២. ទាក់ទងនឹងកម្មកររោងចក្រក្នុងការចុះឈ្មោះបោះឆ្នោត ឯកឧត្តមសង្កេតឃើញថា អាជ្ញាធរមូលដ្ឋានមិនបង្កភាពងាយស្រួលដល់ពួកគេទេ ក្នុងការចេញលិខិតបញ្ជាក់ការស្នាក់នៅដើម្បីឱ្យគ្នាអាចចុះឈ្មោះបាន ព្រោះបើគ្នាធ្វើដំណើរទៅខេត្ត ក៏ត្រូវចំណាយសោហ៊ុយច្រើនដែរ។ បញ្ហានេះគួរត្រូវបានយកទៅពិចារណា ព្រោះបានសម្រាលបន្ទុកកម្មករប្រហែល៣០ម៉ឺននាក់ក្នុងការប្រើ

សិទ្ធិចូលរួមបោះឆ្នោត។ ឯកឧត្តមថ្លែងថា បើសិនពួកគេអាចចុះឈ្មោះបាននៅភ្នំពេញ ពួកគេអាចបោះឆ្នោតឱ្យគណបក្សណាមួយដែលគេស្រឡាញ់នៅភ្នំពេញបានដោយមិនចាំបាច់ធ្វើដំណើរទៅខេត្ត។

លោក **សុក សំអឿន** នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានថ្លែងថា វេទិកានេះហាក់ដូចជានាំគ្នាលើកបញ្ហាឱ្យឯកឧត្តម ទេព នីថា ឆ្លើយ។ លោកយល់ថា កិច្ចប្រជុំពិភាក្សាដើម្បីដោះស្រាយបញ្ហា យើងមិនគួរឱ្យ គជប គាត់ដោះស្រាយ ឬក៏ឆ្លើយបានភ្លាមៗនោះទេ ព្រោះករណីខ្លះ គជប មិនអាចដោះស្រាយដោយខ្លួនឯងបានទេ គឺត្រូវការកែប្រែនីតិវិធី ឬច្បាប់ផ្សេងៗ ដូច្នេះយើងគួរលើកយកបញ្ហាណាមួយដែលត្រូវកែលំអដើម្បីឱ្យ គជប ឬអង្គប្រជុំមានមតិយោបល់បែបណាទាក់ទងនឹងក្របខ័ណ្ឌច្បាប់។

លោក **ឱក សេរី សោភក្តិ** បានថ្លែងថា ការចុះឈ្មោះនេះមានសារៈសំខាន់ណាស់សំរាប់ដំណើរបោះឆ្នោត ហើយលោកទទួលស្គាល់ថា គជប មានការខំប្រឹងប្រែងណាស់។ លោកមានសំណូមពរថា បើសិនធ្វើទៅបានការចុះឈ្មោះលើកក្រោយយើងអាចប្រើកម្លាំងនិស្សិតដែលទើបចេញពីសាលាឱ្យជួយស្មៀនឃុំ-សង្កាត់ក្នុងកិច្ចការនេះ ហើយលោកយល់ថាយើងគ្រាន់តែចំណាយបន្តិចបន្តួចប៉ុណ្ណោះដើម្បីឧបត្ថម្ភពួកគេ ។

ឯកឧត្តម **ទេព នីថា** បានបញ្ជាក់ថា គជប បានយកចិត្តទុកដាក់ណាស់ក្នុងការលើកទឹកចិត្តឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតដើម្បីប្រើសិទ្ធិរបស់គាត់។ ឯកឧត្តមថ្លែងថា គជប ពុំមានលទ្ធភាពបិទបញ្ជីឈ្មោះបោះឆ្នោតតាមការិយាល័យទេនៅពេលចុះឈ្មោះធម្មតានេះ ក៏ប៉ុន្តែនៅពេលបោះឆ្នោត គឺបញ្ជីនេះយើងបិទដល់ការិយាល័យបោះឆ្នោតតែម្តងនៅមុនថ្ងៃបោះឆ្នោត។ បើយើងពិនិត្យមើលនីតិវិធីនៃការចុះឈ្មោះរបស់យើងនេះ គឺវាមិនចង្អៀតចង្អល់ពីបញ្ហាទីលំនៅទេ ព្រោះកម្មករ សិស្ស និស្សិត និងមន្ត្រីរាជការដែលផ្លាស់ទៅធ្វើការនៅខេត្ត-ក្រុងផ្សេងៗ ឬក៏មកនៅទីក្រុងជួលផ្ទះគេនៅគាត់មានកន្លែងស្នាក់នៅពិតប្រាកដ ដូច្នេះគាត់អាចនាំតំណាងពីរនាក់ដែលមានសិទ្ធិបោះឆ្នោតទៅបញ្ជាក់ជាមួយមេឃុំ-ចៅសង្កាត់ដើម្បីធ្វើលិខិតបញ្ជាក់ពីទីលំនៅ និង អាយុដើម្បីចុះឈ្មោះបោះឆ្នោត ដូច្នេះវាមិនចោទជាបញ្ហានោះទេ។ ឯកឧត្តមថ្លែងថា កម្មករកាត់ដេរភាគច្រើនគាត់មានឈ្មោះក្នុងបញ្ជី បោះឆ្នោតរួចហើយ គឺមិនដូចពីមុនទេ ហើយពេលខ្លះគាត់យកប័ណ្ណបោះឆ្នោតទៅចុះឈ្មោះដើម្បីធ្វើការជាកម្មករ ហើយរហូតដល់មាននៅខេត្តខ្លះគេលួចធ្វើប័ណ្ណបោះឆ្នោតក្លែងក្លាយដើម្បីទៅចុះឈ្មោះធ្វើកម្មករទៀតផង ហើយ គជប ធ្លាប់ចាប់បានប៉ុន្មានករណីដែរ ។

ចំពោះករណីសុំច្បាប់អនុញ្ញាតសំរាកទៅចុះឈ្មោះប្រចាំឆ្នាំរបស់កម្មករ ១ថ្ងៃ ឬ២ថ្ងៃនោះ ឯកឧត្តមជឿថាវាមានការលំបាកណាស់ ព្រោះក្រុមហ៊ុនគេរកស៊ី ហើយថ្ងៃបុណ្យជាផ្លូវការនៅស្រុកយើងក៏មានច្រើនគួរសមដែរ។

ចំពោះនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត យើងគិតតាមច្បាប់ដែលមានជាធរមានរាល់ថ្ងៃ គឺមាន២ ដូច្នេះមែន ហើយច្បាប់ទាំងពីរនេះក៏បានចែងពីការចុះឈ្មោះប្រចាំឆ្នាំដែរ ដោយច្បាប់បោះឆ្នោតឃុំ-សង្កាត់ក៏និយាយពីការចុះឈ្មោះប្រចាំឆ្នាំដែរ ក៏ប៉ុន្តែអត់មាននិយាយលំអិតថាអ្នកណាចុះឈ្មោះទេ។ ដោយឡែកច្បាប់បោះឆ្នោតតំណាងរាស្ត្រដែលត្រូវបានធ្វើវិសោធនកម្មនេះ មាននិយាយច្បាស់ថា អ្នកណាត្រូវចុះឈ្មោះ ដូច្នេះហើយបានជាយើងអនុវត្តតាមច្បាប់បោះឆ្នោតតំណាងរាស្ត្រតែម្តង។ ឯកឧត្តមបន្តថា បើសិនជាយើងអនុវត្តធ្វើការពិនិត្យបញ្ជីចុះឈ្មោះប្រចាំឆ្នាំតាមច្បាប់បោះឆ្នោតឃុំ-សង្កាត់នោះ យើងត្រូវបង្កើតគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោតទៀត ដូចនេះវាត្រូវចំណាយថវិកាច្រើនណាស់។

បញ្ហាមួយទៀតដែលខាងគណបក្ស សម រង្ស៊ី បានលើកឡើងអំពីនីតិវិធីក្រោយឆ្នាំ ២០០៤ ឯកឧត្តមបានជំរាបថានីតិវិធីនៃការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត យើងបានអនុម័តថ្មីមួយទៀតនៅក្នុងឆ្នាំ២០០៤ អញ្ចឹងទេនីតិវិធីលើកមុន យើងសរសេរក្នុងការបោះឆ្នោតឆ្នាំ២០០៣ ។ នីតិវិធីមួយៗវាត្រូវធ្វើការកែតំរូវទៅតាមស្ថានភាពជាក់ស្តែង ។ អញ្ចឹងទេក្រោយពីយើងពិនិត្យឃើញ

មានចំណុចខ្វះខាតមួយចំនួន យើងក៏បានអនុម័តនីតិវិធីនៃការចុះឈ្មោះឆ្នាំ ២០០៤ ហើយនីតិវិធីនេះយើងបានផ្សព្វផ្សាយតាំងពីឆ្នាំ ២០០៤ មកហើយ ។ ចំពោះរយៈពេលនៃការចុះឈ្មោះបោះឆ្នោតនេះ ឯកឧត្តមជំរាបថា វាជាការកំណត់នៃច្បាប់ការចុះឈ្មោះបោះឆ្នោត ហើយទើបតែឆ្នាំនេះទេដែលចំនួនថ្ងៃត្រូវបន្ថយ ព្រោះថា បុណ្យចំរើនព្រះជន្មត្រូវកាត់មកធ្វើ១ថ្ងៃវិញ ពីមុន៣ថ្ងៃ ហើយ ២៣ តុលាត្រូវលុបចេញទៀត ដូច្នេះវានៅសល់តែ ១០ ថ្ងៃ ហើយបើយើងគិតប្តឹងដំណាក់កាលទីមួយ ៣១ ថ្ងៃ បិទបញ្ជីបោះឆ្នោតដំបូង១ ថ្ងៃ ប្តឹងដំណាក់កាលទី២ និងដោះស្រាយ ៣៣ថ្ងៃ ដូច្នេះវាកាត់អស់រលីងនៅសល់ពេលចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ២០ ហើយក្នុងហ្នឹងមាន៣ថ្ងៃទៀតចំបុណ្យភ្ជុំបិណ្ឌដែលត្រូវឈប់ ។ បញ្ហាបុណ្យភ្ជុំបិណ្ឌនេះមានការលំបាកដែរ ឧទាហរណ៏ថា មេឃុំ-ចៅសង្កាត់ ឬស្មៀនដែលមានទីលំនៅនៅភ្នំពេញ ហើយគាត់ត្រូវឈប់ដើម្បីទៅស្រុក តែអ្នកនៅខេត្តពួកគាត់មិនចង់ឈប់ទេ ព្រោះគាត់ដឹងថាពេលហ្នឹងមានកម្មករនៅភ្នំពេញ អ្នកណាមិនទាន់ចុះឈ្មោះ ពេលគាត់ត្រឡប់ទៅស្រុកហើយសុំចុះឈ្មោះពេលហ្នឹង តែឱ្យគាត់ធ្វើយ៉ាងម៉េច បើឱ្យគាត់ធ្វើការគឺវាខុស ព្រោះបុណ្យជាតិដែលគេតម្រូវឱ្យឈប់សំរាក តែបើមិនឱ្យធ្វើការអ្នកខ្លះអត់បានចុះឈ្មោះ ដូច្នេះវាមានការលំបាកណាស់។ តែជាក់ស្តែងកន្លងមកនៅឃុំ-សង្កាត់ខ្លះគាត់បានដោះស្រាយបញ្ហានេះបានយ៉ាងច្រើនដែរ។ បញ្ហាមួយទៀតយើងក្តាប់មិនបានទេចំពោះខ្មែរនៅបរទេសមកចុះឈ្មោះបោះឆ្នោត ព្រោះថាយើងអត់បានទាមទារឱ្យដឹងថាគាត់នៅទីណាទេ បើគាត់នៅបរទេសគាត់មានឯកសារបញ្ជាក់ថាខ្មែរ ហើយបើសិនជាគាត់គ្មានទីលំនៅ យើងក៏អត់ចុះឈ្មោះឱ្យដែរ អញ្ចឹងគាត់មកភ្នំពេញគាត់មានផ្ទះណាមួយមានគេបញ្ជាក់សាក្សីយើងចុះឈ្មោះជូនគាត់ ។

ចំពោះសំណូមពរឱ្យគណបក្សជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោត ឯកឧត្តមគិតថា នេះជាសិទ្ធិរបស់គណបក្សនយោបាយ តែកន្លងមក គជប តែងផ្សព្វផ្សាយរហូត តែបើចង់ឱ្យ គជប ណែនាំជាផ្លូវការឱ្យគណបក្សនយោបាយជួយផ្សព្វផ្សាយនោះ គជប មិនធ្វើទេ។ យើងមានពិសោធន៏ហើយបញ្ហានេះ លើកមុនមានគណបក្សមួយបានដាក់មេក្រូផ្សព្វផ្សាយយកខ្លឹមសាររបស់ គជប ទៅបន្ថែមទៀតរហូតដល់មានទំនាស់នឹងគ្នា ហើយបញ្ហានេះស្មុគស្មាញណាស់ បើធ្វើសកម្មភាពដូចជាជូនដំណឹងឱ្យប្រជាពលរដ្ឋលោកទៅបោះឆ្នោត ដូចជាមិនមានបញ្ហាអ្វីទេ តែមានរហូតដល់ធ្វើរូបភាពគណបក្ស និង ដាក់មេក្រូផ្សាយរបៀបជាការឃោសនាទៀត។ ឯកឧត្តមបញ្ជាក់ផងដែរថា ការងារនេះយើងបានជូនដំណឹងតាមរយៈមេឃុំ-ចៅសង្កាត់ ស្មៀន មេភូមិ រហូតដល់មេក្រុមទៀតដើម្បីជូនព័តិមានដល់ប្រជាពលរដ្ឋ។ ហើយបញ្ហាអ្នកស្ម័គ្រចិត្តដែលទៅជួយជូនព័តិមានដល់ប្រជាពលរដ្ឋនោះនៅក្នុងឆ្នាំ ២០០៣មានអង្គការយុវជនមួយគាត់បានស្ម័គ្រចិត្តធ្វើការងារនេះឱ្យ គជប ហើយ គជប បានអនុញ្ញាតឱ្យគាត់ធ្វើ ហើយគាត់ធ្វើបានប៉ុន្មានខេត្តដែរ ដោយគាត់ជូនដំណឹងតាមមេក្រូ និង ចែកខិតបណ្ណ័តាមទីសារធារណៈ ។

បញ្ហាទាក់ទងនឹងឃុំប៉ោយប៉ែត យើងបានយកចិត្តទុកដាក់បញ្ហានេះណាស់ ក៏ប៉ុន្តែយើងនៅតែមានការស្មុគស្មាញដដែល។ នៅឃុំប៉ោយប៉ែតមួយប៉ុណ្ណោះមានការិយាល័យបោះឆ្នោត៦៣ ហើយអ្នកនៅទីនោះភាគច្រើនអត់មានទីលំនៅអចិន្ត្រៃយ៏នៅក្នុងឃុំហ្នឹងទេ ពួកគាត់គ្រាន់តែឆ្លងកាត់រកស៊ី អញ្ចឹងហើយបានជាពេលបោះឆ្នោតឆ្នាំ២០០៣ អ្នកបោះឆ្នោតបានប្រហែលជាង ៥០ ភាគរយប៉ុណ្ណោះ ព្រោះដល់ពេលបោះឆ្នោតគេបិទព្រំដែន អ្នកដែលមានទីលំនៅអចិន្ត្រៃយ៏នៅទីនោះក៏នៅទីនោះដើម្បីបោះឆ្នោត រីឯអ្នកដែលគ្រាន់ តែទៅរកស៊ីក៏ត្រឡប់មកស្រុកវិញ ព្រោះអ្នកខ្លះមិនអាចចុះឈ្មោះបោះឆ្នោតបានដោយគ្មានលិខិតបញ្ជាក់អត្តសញ្ញាណ។

ហើយចំណុចមួយទៀតទាក់ទងនឹងការបោះឆ្នោតនៅបរទេស ឯកឧត្តមជឿថាវាទាក់ទងនឹងបញ្ហាច្បាប់ទេ បើច្បាប់កំណត់មក វាមិនបញ្ហាអ្វីទេ ព្រោះថានីតិវិធី ឬការរៀបចំនៃការបោះឆ្នោតមួយដែលមានអ្នកបោះឆ្នោតនៅបរទេសនោះ គឺយើងគ្រាន់តែធ្វើ

ការកំណត់ទីតាំងការិយាល័យ និងអ្នកមានសិទ្ធិបោះឆ្នោត។ល។ បើសិនច្បាប់កំណត់មក យើងអាចធ្វើបាន ប៉ុន្តែត្រូវចំណាយច្រើនណាស់។

ចំពោះបញ្ហាអ្នកជាប់មន្ទីរឃុំឃាំងបណ្តោះអាសន្ន ដែលតុលាការមិនទាន់ចេញសាលក្រមនោះ ឯកឧត្តមជឿថាមិនមានបញ្ហាអ្វីទេ ឧទាហរណ៍ក្នុងការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០០៣ យើងបានធ្វើការចុះឈ្មោះរហូតដល់មន្ទីរឃុំឃាំង ហើយយើងបានស្នើឱ្យមន្ទីរឃុំឃាំងរាយការណ៍អំពីអ្នកដែលមិនទាន់មានសាលក្រមដើម្បីចុះឈ្មោះជូនគាត់។ តែបញ្ហាលំបាកនៅត្រង់ថាតើអ្នកណាបញ្ជាក់ទីលំនៅឱ្យគាត់។

ចំពោះយោបល់របស់លោក សុក សំអឿន ឯកឧត្តមសូមឯកភាព ព្រោះកន្លងមកឯកឧត្តមត្រូវប្រឈមមុខឆ្លើយរហូត ហើយឯកឧត្តមអត់មាននិយាយអ្វីលើសពីច្បាប់ដែលមានចែងទេ និងអត់មាននិយាយអ្វីលើសពីអំណាច និងសិទ្ធិ របស់ គជប នោះទេ។

## ៥. បញ្ហាអត្តសញ្ញាណប័ណ្ណ (ការពិភាក្សាបន្តពីខប់សែលលើកមុន)

ឯកឧត្តម ឧត្តមសេនីយ៍ ណុប ស៊ីណូ តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ បានជំរាបជូនអង្គប្រជុំថា ការផ្តល់អត្តសញ្ញាណប័ណ្ណនេះ វាភ្ជាប់ទៅនឹងការស្រង់បញ្ជីស្ថិតិប្រជាពលរដ្ឋ ហើយការស្រង់បញ្ជីស្ថិតិ គឺមានតារាង ក១ ក២ ក៣ រហូតដល់ ក៩ ដែលជានីតិវិធីរបស់សមត្ថកិច្ចនគរបាលជាតិ។ ការងារអត្តសញ្ញាណប័ណ្ណនេះមានសារៈសំខាន់ណាស់ ព្រោះវាជាយន្តការបំរើមួយផ្នែកនៃការចុះបញ្ជីបោះឆ្នោតសំរាប់អ្នកបោះឆ្នោត និងបេក្ខជន។ ការផ្តល់អត្តសញ្ញាណបណ្ណ័នេះ យើងមានក្រុមហ៊ុន ២ ជាអ្នកផលិតដោយមានការយល់ព្រមពីរដ្ឋាភិបាល និងមានកិច្ចសន្យារវាងក្រសួងមហាផ្ទៃ និងក្រុមហ៊ុន។ ការផ្តល់ដំណាក់កាលទីមួយគឺ ៥លាន សំរាប់ ២៤ ខេត្ត-ក្រុង ដោយក្រុមហ៊ុនមួយទទួល ១លាន សំរាប់ ៩ ខេត្ត-ក្រុង រីឯក្រុមហ៊ុនមួយទៀតទទួល ៤លាន សំរាប់ ១៥ ខេត្ត-ក្រុង។ យើងបានស្រង់បញ្ជីមកទល់នឹងថ្ងៃទី ៣០ កញ្ញា ២០០៥ នេះ ចំពោះអ្នកដែលអាចផ្តល់នូវអត្តសញ្ញាណប័ណ្ណបាន គឺចំនួន ៦.៩៩៤.៨៣១ នាក់ លើចំនួនអ្នកដែលមានសិទ្ធិធ្វើអត្តសញ្ញាណប័ណ្ណជាង ៧លាននាក់។ មកទល់នឹងថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៥ នេះដែរ ប្រជាពលរដ្ឋបានបំពេញបែបបទ និងឯកសារពាក់ព័ន្ធសំរាប់ធ្វើអត្តសញ្ញាណប័ណ្ណរួចគឺមានចំនួន ៥.៤៩៤.១៥៨ នាក់ ។

ឯកឧត្តមបានបន្តថា ក្រុមហ៊ុនបានផលិតអត្តសញ្ញាណប័ណ្ណបានចំនួន ៥.៤៥៥.៦៦២ ហើយអត្តសញ្ញាណប័ណ្ណដែលចុះហត្ថលេខារួចបានចំនួន ៥.០៤៣.១៧៤ ហើយចំនួន ៥.០៤១.១៨៩ បានចែកដល់ដៃប្រជាពលរដ្ឋរួចហើយ។ ដូច្នេះប្រជាពលរដ្ឋបានទទួលអត្តសញ្ញាណប័ណ្ណមានចំនួនប្រហែល ៩៥ ភាគរយហើយ។ ឯកឧត្តមថ្លែងថា មានអត្តសញ្ញាណប័ណ្ណប្រហែល ៣០ ម៉ឺនទៀតកំពុងរង់ចាំការចុះហត្ថលេខារបស់ឯកឧត្តមអភិបាលខេត្ត-ក្រុង។ ទាក់ទងនឹងបញ្ហាអត្តសញ្ញាណប័ណ្ណនេះ ឯកឧត្តមបញ្ជាក់ថា បើសិនមានសមាជិកអង្គប្រជុំណា ឬអង្គការណាដែលចង់ស្វែងយល់ឱ្យស៊ីជំរៅអំពីការងារនេះ ឯកឧត្តមមានសេចក្តីរីករាយ និងត្រៀមខ្លួនដើម្បីជំរាបជូននៅការិយាល័យរបស់ឯកឧត្តម។ ដើម្បីទទួលបានអត្តសញ្ញាណប័ណ្ណ ទាល់តែជាជនជាតិខ្មែរ ហើយមានអាយុគ្រប់តាមច្បាប់កំណត់ ។ ដើម្បីឱ្យការផ្តល់នេះមានភាពរលូន ឯកឧត្តមបានបង្កើតគណៈកម្មការពិសេសមួយចុះគ្រប់ខេត្ត-ក្រុងដើម្បីពិនិត្យមើលថាតើអ្នកមកសុំធ្វើអត្តសញ្ញាណប័ណ្ណនោះជាជនជាតិខ្មែរមែនឬមិនមែន ក៏ដូចជាចង់ដឹងថាតើការផ្តល់ប័ណ្ណនោះមានភាពមិនប្រក្រតីដូចម្តេចខ្លះ។ តែទោះបីយ៉ាងណាក៏ដោយ ឯកឧត្តមថ្លែងថា ភាពខុសឆ្គងដោយអចេតនាខ្លះពិតជាមានមែន ដូចជាឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើតសរសេរខុស។ ដោយឡែក ចំពោះតួលេខប្រជាពលរដ្ឋស្រង់ដោយប៉ូលិសមិនស៊ីគ្នាជាមួយនឹងតួលេខដែលស្រង់ដោយ គជប នោះ ឯកឧត្តមថ្លែងថា ខាងប៉ូលិសមាននីតិវិធីស្រង់យ៉ាងច្បាស់លាស់ ឧទាហរណ៍ មុននឹងសំរេចចុះឈ្មោះអ្នកណាម្នាក់ទាល់តែអ្នកនោះ

មានទីលំនៅអចិន្ត្រៃយ៍៦ខែ ហើយបើអ្នកណាម្នាក់ផ្លាស់ប្តូរទីលំនៅយើងទុកចន្លោះ៦ខែ ទើបយើងសំរេចលុបឈ្មោះគាត់ចេញពីបញ្ជី ។ ដូច្នេះតួលេខរបស់ប៉ូលិសគឺមានភាពច្បាស់លាស់ដោយឈរលើភាពជាក់ស្តែង ។

លោក **ឱក សេរី សោភក្តិ៍** បានធ្វើការបូកសរុបលទ្ធផលនៃការពិភាក្សាក្នុងកិច្ចប្រជុំខប់សែលខម់លើកទី៣នេះដូចខាងក្រោម :

១. ការពិភាក្សាកែលំអអំពីនីតិវិធីបែបបទនៃការត្រួតពិនិត្យកំណត់ហេតុអង្គប្រជុំខប់សែល ។

២. ស្វាគមន៏ដល់គណបក្ស សម រង្ស៊ី ដែលបានលើកសំណើរបៀបវារៈសំរាប់កិច្ចប្រជុំលើកក្រោយ ទី១ការពិនិត្យបញ្ជីចុះឈ្មោះបោះឆ្នោតដំបូង និង ទី២ ការពិនិត្យនីតិវិធីក្នុងការរៀបចំការបោះឆ្នោត ។

៣. ស្តាប់របាយការណ៏ និង ធ្វើការពិភាក្សាអំពីការរៀបចំបោះឆ្នោតព្រឹទ្ធសភា ព្រមទាំងស្តាប់នូវព័ត៌មានខាងគណបក្សប្រ-ជាធិបតេយ្យ ដែលលោកមានឆន្ទៈនយោបាយពិតប្រាកដក្នុងការចូលរួមនៅក្នុងយន្តការប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ហើយក្នុងបញ្ហានេះមានបញ្ហាពីរដែលយើងគិតថានៅចំរូងចំរាស់នៅឡើយ គឺទី១បញ្ហាអ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ដែលអាចមានការផ្លាស់ប្តូរ ហើយដែល គជប ក្តី គណបក្សក្តី មិនទាន់បានទទួលព័ត៌មានទាក់ទងទៅនឹងបច្ចុប្បន្នភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាអ្នកត្រូវបោះឆ្នោតនៅក្នុងការបោះឆ្នោតព្រឹទ្ធសភាខាងមុខ ។ ទី២ទាក់ទងទៅនឹងបញ្ហាតំណាងរាស្ត្ររបស់គណបក្ស សម រង្ស៊ី ដែលគណបក្សបានលុបឈ្មោះចេញពីគណបក្សហើយ ប៉ុន្តែតំណាងរាស្ត្រនោះនៅតែទទួលស្គាល់ដោយរដ្ឋសភាមិនទាន់បានលុប ។ នីតិវិធីនៃការដោះស្រាយបញ្ហានេះ គឺខាង គជប និងខាងរដ្ឋសភាប្រហែលជាអាចនឹងធ្វើការពិភាក្សាគ្នា ។

៤. ស្តាប់របាយការណ៏អំពីការចុះឈ្មោះបោះឆ្នោត ក្នុងនោះមានតួលេខខុសគ្នារវាង គជប និង ក្រសួងមហាផ្ទៃ និងរវាងក្រុមប្រឹក្សាឃុំ-សង្កាត់ និង ក្រសួងផែនការ ។ យើងបានឃើញថា ជំហានឆ្នាំដំបូងនេះលទ្ធផលបានស្មើរតែប្រហាក់ប្រហែល ៥០% ។ ដូចនេះការជូនដំណឹងដល់ប្រជាពលរដ្ឋឱ្យមកចុះឈ្មោះបោះឆ្នោតនេះ គឺនៅមានកិច្ចការដែលត្រូវធ្វើច្រើនណាស់ ហើយបញ្ហានេះមានទាក់ទងទៅនឹងការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតឃុំ-សង្កាត់ និង ច្បាប់បោះឆ្នោតតំណាងរាស្ត្រផងដែរ ។ បញ្ហាមួយទៀតនៅក្នុងចំណុចនេះ យើងបានពិភាក្សាទាក់ទងទៅនឹងបញ្ហាថា និស្សិត និងកម្មករ ដែលបានចុះឈ្មោះនៅខេត្ត ហើយមិនអាចសុំច្បាប់ទៅចុះឈ្មោះបោះឆ្នោតបាន ពេលដែលខ្លួនបានទៅរស់នៅឬធ្វើការនៅទីកន្លែងផ្សេង ។

៥. យើងបានស្តាប់របាយការណ៏ស្ថិតិ និងតួលេខដែលផ្តល់ដោយឯកឧត្តម ឧត្តមសេនីយ៏ទោ ណុប ស៊ីណូ ទាក់ទងទៅនឹងបញ្ហាអត្តសញ្ញាណប័ណ្ណ ។ លោកបញ្ជាក់ថា ប្រជាពលរដ្ឋដែលមានសិទ្ធិបានទទួលអត្តសញ្ញាណប័ណ្ណមានប្រហែលជាង៧លាននាក់ ហើយមកទល់ពេលនេះយើងគិតថា អ្នកដែលបានទទួលប័ណ្ណបានប្រហែលជិត៦លាននាក់ហើយ ហើយនៅប្រហែល៣សែនសន្លឹកទៀត ដែលមិនទាន់ចុះហត្ថលេខាដោយឯកឧត្តមអភិបាលខេត្ត-ក្រុង ។ ឯកឧត្តម ឧត្តមសេនីយ៏ក៏បានទទួលស្គាល់ផងដែរអំពីភាពខុសគ្នានៃតួលេខរវាងក្រសួងមហាផ្ទៃ និង គជប ។

**កាលបរិច្ឆេទនៃកិច្ចប្រជុំ ខប់សែលខម – COPCELCOM លើកទី ៤ នឹងប្រព្រឹត្តទៅថ្ងៃទី ២៩ វិច្ឆិកា ២០០៥**

**នៅវិទ្យាស្ថាន CDRI ។**